ធនាគារអភិវឌ្ឍន៍ជនបទ
RURAL DEVELOPMENT BANK

របាយការណ៍ប្រចាំឆ្នាំ

២០១៨

ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

តារាងមាតិកា

I. អំពីធនាគារអភិវឌ្ឍន៍ជនបទ

៥	ប្រវត្តិធនាគារអភិវឌ្ឍន៍ជនបទ
៦	សារលិខិតរបស់អគ្គនាយក
១០	ទិន្នន័យហិរញ្ញវត្ថុសង្ខេប
១១-១៦	ព្រឹត្តិការណ៍នៃធនាគារអភិវឌ្ឍន៍ជនបទ

II. អភិបាលកិច្ចសាជីវកម្ម

១៩	ការគ្រប់គ្រងហានិភ័យនិងការត្រួតពិនិត្យផ្ទៃក្នុង
២១	រចនាសម្ព័ន្ធធនាគារអភិវឌ្ឍន៍ជនបទ
២៣-២៧	ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល
២៨-៣០	ប្រវត្តិរូបសង្ខេបរបស់គណៈគ្រប់គ្រង

III. របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

៣៣-៣៦	របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
៣៧	សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាភិបាល
៣៨-៤១	របាយការណ៍របស់សវនករឯករាជ្យ

របាយការណ៍ហិរញ្ញវត្ថុ

៤២-៤៣	តារាងតុល្យការ
៤៤	គណនីលទ្ធផល
៤៥	របាយការណ៍ចរន្តមូលនិធិម្ចាស់ភាគហ៊ុន
៤៦	របាយការណ៍ចរន្តសាច់ប្រាក់
៤៧-៨៦	កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ

I. អំពីធនាគារអភិវឌ្ឍន៍ជនបទ

៥ ប្រវត្តិធនាគារអភិវឌ្ឍន៍ជនបទ

៦ សារលិខិតរបស់អគ្គនាយក

១០ ទិន្នន័យហិរញ្ញវត្ថុសង្ខេប

១១-១៦ ព្រឹត្តិការណ៍នៃធនាគារអភិវឌ្ឍន៍ជនបទ

ធនាគារអភិវឌ្ឍន៍ជនបទ (ធ.អ.ជ.)

ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨ និងត្រូវបាននិរាករណ៍ដោយអនុក្រឹតលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីធនាគារអភិវឌ្ឍន៍ជនបទ ក្នុងគោលបំណងបំពេញនូវកង្វះខាតរវាងតម្រូវការ និងការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅតំបន់ជនបទ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ធ.អ.ជ. ត្រូវបានកំណត់ជាសហគ្រាសសាធារណៈក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាគ្រឹះស្ថានធនាគារ និងមានស្វ័យភាពបរិបូណ៌ក្នុងការដឹកនាំនិងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។ ធ.អ.ជ. ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

ចក្ខុវិស័យ

ចក្ខុវិស័យនៃធនាគារអភិវឌ្ឍន៍ជនបទ គឺប្រែក្លាយទៅជា "ធនាគារកសិកម្មនៃកម្ពុជា" ឈានមុខដែលមានចំណាត់ថ្នាក់ជាធនាគារពាណិជ្ជ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ តាមរយៈការផ្តល់ហិរញ្ញប្បទាន ដល់តួអង្គក្នុងខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម សំដៅរួមចំណែកបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាកសិករតាមទីជនបទ និងរួមចំណែកកសាងសេដ្ឋកិច្ចសង្គម។

បេសកកម្ម

ធនាគារអភិវឌ្ឍន៍ជនបទ មានបេសកកម្មជំរុញហិរញ្ញប្បទាន ដល់គ្រប់ដំណាក់កាលនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម ក្នុងសកម្មភាពដូចតទៅ៖

- ផ្តល់ឥណទានដល់ក្រុមហ៊ុន សហគ្រាសខ្នាតតូចនិងមធ្យម អង្គការកសិករ ឬសហគមន៍កសិកម្ម ដែលជានីតិបុគ្គលដែលស្ថិតនៅក្នុងខ្សែច្រវ៉ាក់ផលិតកម្មកសិកម្មពាក់ព័ន្ធនឹងវិស័យកសិកម្មនិងសេដ្ឋកិច្ចជនបទ រួមមាន ជាអាទិ៍ ការផលិត ការស្តុកទុក ការកែច្នៃ ការចែកចាយ និងការនាំចេញនូវផលិតផលកសិកម្ម ជាពិសេសអង្ករ និងផ្នែកផ្សេងទៀតដែលផ្សារភ្ជាប់នឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងកសិកម្ម និងសេដ្ឋកិច្ចសង្គម
- ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដែលមានសកម្មភាពទ្រទ្រង់សេដ្ឋកិច្ចជនបទ
- ធ្វើសហជីវការ (Syndicate) ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ក្នុងការផ្តល់ឥណទាន ដើម្បីអនុវត្តគម្រោងក្នុងវិស័យកសិកម្ម អនុវិស័យ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងកសិកម្ម និងសេដ្ឋកិច្ចសង្គម
- អនុវត្តគម្រោងឥណទាន ឬគ្រប់គ្រងមូលនិធិផ្សេងទៀត ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍
- គ្រប់គ្រងកម្មវិធី ឬគម្រោងពិសេសណាមួយរបស់រាជរដ្ឋាភិបាល ឬ គម្រោងពិសេសផ្សេងៗទៀតដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចរចាជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីទាក់ទាញហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានសម្រាប់ពង្រីកសកម្មភាពរបស់ធ.អ.ជ.៕

ឯកឧត្តម កៅ ថាច
អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ

ធនាគារអភិវឌ្ឍន៍ជនបទ (ធ.អ.ជ.) ដែលជាធនាគារមិនស្វែងរកប្រាក់ចំណេញក្នុងកម្រិតអតិបរមា ដូចគ្រឹះស្ថានធនាគារឯកជន បាននិងកំពុងពង្រីកការគាំទ្រការអភិវឌ្ឍវិស័យកសិកម្ម ចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម តាមរយៈការផ្តល់ហិរញ្ញប្បទានលើវិស័យស្រូវ-អង្ករ ការធ្វើពិពិធកម្មលើអនុវិស័យដំណាំបន្លែនិងការចិញ្ចឹមសត្វ ស្របនឹងការរៀបចំគម្រោងប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទទៅជា*ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម* ដែលបំពេញមុខងារជាធនាគារពាណិជ្ជផង និងធនាគារបម្រើគោលនយោបាយផង ដែលអាចដោះស្រាយបញ្ហាបរាជ័យទីផ្សារ បំពេញនូវកង្វះខាតរវាងតម្រូវការនិងការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ។

ក្នុងនាមជាធនាគាររដ្ឋ បម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងវិស័យកសិកម្មនិងសេដ្ឋកិច្ចជនបទ **ធ.អ.ជ.** បានប្រកាន់ខ្ជាប់នូវទស្សនៈវិស័យ និងបេសកកម្មចម្បងរបស់ខ្លួនក្នុងការចូលរួមបង្កើតការងារ និងលើកកម្ពស់ជីវភាពប្រជាជននៅតាមទីជនបទ តាមរយៈនៃការផ្តល់ឥណទានដល់គ្រប់តួអង្គនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម រួមមានជាអាទិ៍ ការផលិត ការស្តុកទុក ការកែច្នៃ ការចែកចាយ និងការនាំចេញនូវផលិតផលកសិកម្ម ជាពិសេសអង្ករ។

ធ.អ.ជ. បានជំរុញនិងពង្រីកបាននូវកំណើនឥណទានគួរឱ្យកត់សម្គាល់ ដែលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ **ធ.អ.ជ.** សម្រេចបាននូវកំណើនឥណទាន ៣០% ធៀបឆ្នាំ២០១៧ ក្នុងនោះសម្មៀតឥណទានបានគាំទ្រដល់វិស័យស្រូវ-អង្ករ រួមទាំង ឃ្លាំងស្តុក និងឡសម្ងួតស្រូវ ចំនួន៧៦,១៣% អនុវិស័យ រួមមានៈ កៅស៊ូ ម្រេច កាហ្វេ ដំឡូងមី អំពៅ ពោត ចំនួន ១៤,៨៩% និងមីក្រូហិរញ្ញវត្ថុ ការចិញ្ចឹមសត្វនិងផ្សេងៗចំនួន ៨,៩៧%។ ទំហំអាជីវកម្មក៏បានឆ្លុះបញ្ចាំងអំពីភាពរឹងមាំនៃលទ្ធផលសម្រេចបានផ្នែកហិរញ្ញវត្ថុផងដែរ។ **ធ.អ.ជ.** ទទួលបានកំណើនលើចំណូលដុល កើនឡើង៤៣% លទ្ធផលក្រោយបង់ពន្ធកើនឡើងដល់១៦៩% និងទ្រព្យសកម្មសរុបកើន១៤% ធៀបនឹងឆ្នាំ២០១៧។

ធ.អ.ជ. បានចូលរួមចំណែកដោះស្រាយបញ្ហាធ្លាក់ចុះនៃតម្លៃស្រូវ និងរក្សានូវស្ថិរភាពតម្លៃស្រូវ តាមរយៈការផ្តល់ការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពី **រាជរដ្ឋាភិបាលកម្ពុជា** តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចដាក់ចេញនូវយន្តការអន្តរាគមន៍រយៈពេលខ្លី **"កម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល"** ដែលមានកញ្ចប់ថវិកាពិសេសសរុប ចំនួន**៥០លានដុល្លារអាមេរិក** ក្នុងនោះរួមចំណែកពីកញ្ចប់ថវិកាជាតិចំនួន **៤៣ លានដុល្លារអាមេរិក** និងមូលនិធិផ្ទាល់របស់ **ធ.អ.ជ.** ចំនួន **៧ លានដុល្លារអាមេរិក** ដើម្បីផ្តល់ឥណទានដល់រោងម៉ាស៊ីន-កិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ សំដៅជំរុញការទិញស្រូវនារដូវប្រមូលផលពីប្រជាកសិករ និងរក្សាស្ថេរភាព-រូបនីយកម្មថ្លៃស្រូវក្នុងប្រទេស។ តាមរយៈកញ្ចប់ថវិកានេះ ធនាគារអភិវឌ្ឍន៍ជនបទដែលជាប្រតិបត្តិករបានធ្វើការផ្តល់ឥណទានជាទុនបង្វិល ដោយទទួលយកសន្និធិស្រូវអង្ករ និង/ ឬ លិខិតធានាសងបំណុលពីភាគីអ្នកទិញជាវត្ថុធានាបំណុលដល់បណ្តារោងម៉ាស៊ីនកិនស្រូវ ដើម្បីធ្វើការប្រមូលទិញស្រូវសែនក្រអូប និងស្រូវម្លិះ-រំដួល ពីប្រជាកសិករតាមតម្លៃសមរម្យ និងរក្សាបាននូវស្ថិរភាពថ្លៃស្រូវជូនប្រជាកសិករ។

ទន្ទឹមនេះ **រាជរដ្ឋាភិបាលកម្ពុជា** តាមរយៈ **ធ.អ.ជ.** បានសម្រេចរៀបចំគម្រោង និងផ្តល់ហិរញ្ញប្បទាន ក្នុងទំហំទឹកប្រាក់ **៣០លានដុល្លារ**ក្នុងការសាងសង់មជ្ឈមណ្ឌលទិញស្រូវ និងបំពាក់គ្រឿងបរិក្ខារផ្សេងៗទៀត ដោះស្រាយបាននូវបញ្ហាហេដ្ឋារចនាសម្ព័ន្ធវិស័យស្រូវ-អង្ករ ដើម្បីបម្រើដល់ការទិញ-លក់ស្រូវ ក្រោមរូបភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ក្នុងនោះ **១៥ លានដុល្លារ** សម្រាប់សាងសង់មជ្ឈមណ្ឌលទិញស្រូវ ដែលឃ្លាំងមានសមត្ថភាពស្តុកទុកស្រូវយ៉ាងតិច **២០០.០០០ តោន** និងឡសម្ងួតដែលមានសមត្ថភាពសម្ងួតស្រូវ **៣.០០០ តោន** ក្នុង១ថ្ងៃ មានទីតាំងនៅខេត្តបាត់ដំបង ដែលអាចបម្រើដល់ភូមិភាគពាយព្យនៃកម្ពុជា (ខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប) និងតំបន់ខេត្តចំនួន ៣ ផ្សេងទៀត គឺតំបន់ខេត្តកំពង់ធំ ព្រៃវែង និងតាកែវ ចំនួន **១៥ លានដុល្លារ** ដើម្បីសាងសង់មជ្ឈមណ្ឌលទិញស្រូវ ដែលឃ្លាំងមានសមត្ថភាពស្តុក - ទុកស្រូវយ៉ាងតិច **៥០.០០០ តោន** និងឡសម្ងួតដែលមានសមត្ថភាពសម្ងួតស្រូវ **១.៥០០ តោន** ក្នុង១ថ្ងៃ នៅតាមទីតាំងនៃតំបន់ខេត្តនីមួយៗ។ គម្រោងឃ្លាំងស្តុក និងឡសម្ងួតស្រូវទាំងនេះ បានបញ្ចប់តាមការគ្រោងទុក និងដាក់សម្ពោធឱ្យប្រើប្រាស់ក្នុងខែកក្កដា ឆ្នាំ២០១៨ ហើយបានជួយរួមចំណែកបង្កើនសមត្ថភាពស្តុក និងកិនកែច្នៃស្រូវ-អង្ករនៅក្នុងតំបន់សំខាន់ៗផលិតស្រូវនៃប្រទេស ជាចម្បងបម្រើឱ្យការនាំចេញ។ កិច្ចអន្តរាគមន៍ក្រោមកម្មវិធីពិសេសនេះទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយបានរួមចំណែកធ្វើឱ្យតម្លៃស្រូវរបស់ប្រជាកសិករកើនឡើងគួរកត់សម្គាល់ ព្រមទាំងមានការអបអរសាទរយ៉ាងខ្លាំងពីសំណាក់ប្រជាកសិករ។

ក្រៅពីវិស័យស្រូវ-អង្ករ **ធ.អ.ជ.** បាននិងកំពុងអនុវត្តគម្រោងហិរញ្ញប្បទានពិពិធកម្មលើអនុវិស័យកសិកម្មដំណាំបន្លែ ក្នុងគោលដៅជំរុញផលិតកម្មបន្លែរបស់ប្រជាកសិករនិងសហគមន៍ដាំបន្លែនៅប្រទេសកម្ពុជា ដើម្បីធានានូវសុខុមាលភាពដល់ប្រជាជនហូបបន្លែ ជួយកាត់បន្ថយការនាំចូលបន្លែ និងដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាកសិករដាំដុះបន្លែ។ តាមរយៈនេះ គម្រោងមានការចូលរួមពីក្រុមហ៊ុនទទួលទិញបន្លែ ដែលជាក្រុមហ៊ុនឯកជន ហើយ **ធ.អ.ជ.** ជាអ្នកផ្តល់ហិរញ្ញប្បទានក្នុងអត្រាការប្រាក់អនុគ្រោះដល់បណ្តាកសិករ សហគមន៍ដាំបន្លែ ព្រមទាំង **ធ.អ.ជ.** មានគាំទ្រដល់ក្រុមហ៊ុនទទួលទិញឯកជន ដែលមានតម្រូវការហិរញ្ញវត្ថុគាំទ្រគម្រោងផងដែរ។ **ធ.អ.ជ.** ក៏បាននិងកំពុងជំរុញការអនុវត្តកិច្ចសន្យាកសិកម្ម ធានាបានទីផ្សារសម្រាប់កសិករ តាមរយៈការអនុវត្តគម្រោងហិរញ្ញប្បទានតាមកិច្ចសន្យាពាភាគីលើការចិញ្ចឹមជ្រូកនិងមាន់ ដោយ **ធ.អ.ជ.** ជាអ្នកផ្តល់កម្ចីជាទុនក្នុងអត្រាការប្រាក់សមរម្យដល់អ្នកចិញ្ចឹម និងមានការចូលរួមពីក្រុមហ៊ុនឯកជន ជាអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្មនិងជាអ្នកប្រមូលទិញជ្រូកនិងមាន់ធំរស់ពីអ្នកចិញ្ចឹមវិញ។ តាមរយៈគម្រោងនេះ កសិករទទួលបានអត្រាប្រាក់ចំណេញប្រមាណពី ១១% - ១៧% សម្រាប់ការចិញ្ចឹម១វគ្គ។

ក្នុងឆ្នាំ២០១៨នេះផងដែរ ទន្ទឹមនឹងការសម្រេចបានការពង្រីកបណ្តាញចែកចាយសេវាឥណទានឱ្យកាន់តែជិតអតិថិជននៅតាមទីជនបទ តាមរយៈការបង្កើតការិយាល័យចល័ត ៣បន្ថែម នៅខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ និងខេត្តព្រៃវែង **ធ.អ.ជ.** សម្រេចបានការរៀបចំផែនទីចង្អុលផ្លូវប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ ទៅជា **ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម** ដែលបំពេញមុខងារជាធនាគារពាណិជ្ជផង និងធនាគារបម្រើគោលនយោបាយផង ហើយអាចដោះស្រាយបញ្ហាបរាជ័យទីផ្សារ ពោលគឺបំពេញនូវកង្វះខាតរវាងតម្រូវការ និងការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ ជាពិសេសពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទាននិងសេវាកម្មធនាគារគាំទ្រដល់ខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម។ ផែនទីចង្អុលផ្លូវនេះផ្តោតលើកំណែទម្រង់លើផ្នែកសំខាន់ៗនៃធនាគារ ដែលធ្វើឱ្យ **ធ.អ.ជ** មានលទ្ធភាពបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយជោគជ័យនិងចីរភាព សមស្របតាមការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ និងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។

ដំណើរឆ្ពោះទៅមុខ

ធនាគារអភិវឌ្ឍន៍ជនបទនឹងរៀបចំខ្លួនប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ ទៅជា **ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម** ដែលបំពេញមុខងារជាធនាគារពាណិជ្ជផង និងធនាគារបម្រើគោលនយោបាយផង ការពង្រឹងនិងពង្រីកវិសាលភាពប្រតិបត្តិការធនាគារ តាមរយៈការបង្កើតបណ្តាញសាខា ឬការិយាល័យចល័ត ការគាំទ្រហិរញ្ញប្បទានវិស័យស្រូវ-អង្ករនិងពិពិធកម្មដល់អនុវិស័យក្រៅពីស្រូវ-អង្ករ ការពង្រឹងប្រព័ន្ធធនាគារស្នូល និងព័ត៌មានវិទ្យាធនាគារ ការអនុវត្តធនាគារឌីជីថល ការអនុវត្តគម្រោងហិរញ្ញប្បទានក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនានា និងការធ្វើពិពិធកម្មប្រភពទុន តាមរយៈប្រភពទុនពីរាជរដ្ឋាភិបាល កម្ចីសម្បទានពីស្ថាប័នហិរញ្ញវត្ថុ និង/ ឬដៃគូអភិវឌ្ឍន៍នានា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងនូវការកោតសរសើរយ៉ាងស្មោះ និងអំណរគុណចំពោះក្រុមប្រឹក្សាភិបាលដែលតែងតែគាំទ្រនិង ផ្តល់អនុសាសន៍ដឹកនាំកិច្ចដំណើរការរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងសូមអរគុណចំពោះនិយោជិត **ធ.អ.ជ.** ទាំងអស់ដែលបានខិតខំបំពេញការងារអស់ពីកំលាំងកាយចិត្ត ព្រមទាំងអរគុណចំពោះអតិថិជននិងដៃគូអភិវឌ្ឍន៍នានា ដែលបានចូលរួមសហការជាមួយ **ធ.អ.ជ.** លើកស្ទួយការអភិវឌ្ឍវិស័យកសិកម្មនៃប្រទេសកម្ពុជា។

ខ្ញុំសូមសម្តែងនូវការគោរពនិងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **រាជរដ្ឋាភិបាលកម្ពុជា** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលតែងតែគាំទ្រនិងផ្តល់ទំនុកចិត្តមកធនាគារអភិវឌ្ឍន៍ជនបទ។

ឯកឧត្តម កៅ ថាច

អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ

ទិន្នន័យហិរញ្ញវត្ថុសង្ខេប

តារាងសង្ខេបទិន្នន័យហិរញ្ញវត្ថុសម្រាប់រយៈពេល៣ឆ្នាំ

ការគូសបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ (គិតជាដុល្លារអាមេរិក)	2018	2017	2016
ចំណូលដុល	9,391,151	6,587,783	4,088,646
ចំណូលប្រតិបត្តិការមុនសំវិធានធន	4,889,002	2,799,915	1,447,886
លទ្ធផលមុនបង់ពន្ធ	3,353,915	1,153,088	629,739
លទ្ធផលក្រោយបង់ពន្ធ	2,564,287	953,254	536,336
ចំណុចសំខាន់ៗក្នុងតារាងតុល្យការ (គិតជាដុល្លារអាមេរិក)			
ទ្រព្យសកម្មសរុប	178,281,305	157,535,361	100,442,088
ដើមទុន	44,586,597	41,759,172	37,611,397
កម្ចី និងបុរេប្រទាន (ដុល)	159,115,208	122,070,986	71,583,770
អនុបាតហិរញ្ញវត្ថុ (គិតជា%)			
ផលចំណេញលើដើមទុន	5.75	2.28	1.43
ផលចំណេញលើទ្រព្យសកម្ម	1.44	0.61	0.53
ឥណទានមិនដំណើរការធៀបនឹងឥណទានសរុប	3.58	3.16	6.94
អនុបាតសោធនភាព	28.41	34.10	51.00





ព្រឹត្តិការណ៍នៃធនាគារអភិវឌ្ឍន៍ជនបទ

៨ មីនា ២០១៨

ធនាគារអភិវឌ្ឍន៍ជនបទ អបអរសាទរ **ទិវាសិទ្ធនារីអន្តរជាតិ** ៨មីនា ខួបលើកទី១០៨ ក្រោមប្រធានបទ " លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស "។ ទន្ទឹមនេះ ធនាគារអភិវឌ្ឍន៍ជនបទមានជូនជាថវិកាមួយចំនួនលើកទឹកចិត្ត ដល់និយោជិតនារីៗក្នុងឱកាលទិវាសិទ្ធិនារីអន្តរជាតិ ផងដែរ។

កម្មវិធីប្រគល់-ទទួលកំព្យូទ័រ ដែលជាអំណោយរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងផ្សព្វផ្សាយពីគោលការណ៍ឥណទាន និងភ្ជាប់ទីផ្សាររវាងសហគមន៍កសិកម្ម អ្នកផលិត និងអ្នកទទួលទិញ

កម្មវិធីប្រគល់កុំព្យូទ័រជូនសហគមន៍នៅខេត្តកំពង់ធំ
នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨

កម្មវិធីប្រគល់កុំព្យូទ័រជូនសហគមន៍នៅខេត្តតាកែវ
នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨

ឯកឧត្តម កៅ ថាច អគ្គនាយក នៃធនាគារអភិវឌ្ឍន៍ជនបទ និងសហការី បានអញ្ជើញចូលរួមក្នុងកម្មវិធីសំណេះសំណាលជាមួយបងប្អូនសមាជិកសហគមន៍ ដើម្បីផ្សព្វផ្សាយអំពីព័ត៌មាននៃការតភ្ជាប់ទីផ្សាររវាងសហគមន៍កសិកម្ម អ្នកផលិត និងអ្នកទទួលទិញ និងផ្សព្វផ្សាយអំពីគោលការណ៍ឥណទានសហគមន៍ ព្រមទាំងប្រគល់កំព្យូទ័រជូនដល់សហគមន៍ ក្រោមគម្រោងអង្គការ HEIFER INTERNATIONAL CAMBODIA ដែលមានកុំព្យូទ័រសរុបចំនួន៤០គ្រឿងផងដែរ ក្នុងនោះមានសហគមន៍នៅខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ សីហនុ កំពត និងខេត្តតាកែវ។ ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តម កៅ ថាច បានធ្វើការជម្រាបជូនដល់សមាជិកសហគមន៍អំពីការខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់របស់ **រាជរដ្ឋាភិបាល** លើវិស័យកសិកម្មជាពិសេសបានដោះស្រាយបញ្ហារបស់ប្រជាកសិករ ក្នុងនោះការទំលាក់ទុនជាបន្តបន្ទាប់តាមរយៈធនាគារអភិវឌ្ឍន៍ជនបទដើម្បីធ្វើបានផ្តល់ឥណទានដល់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុននាំចេញស្រូវ-អង្ករ និងដល់សហគមន៍កសិករដោយយកអត្រាការប្រាក់ទាប។ បន្ថែមលើនេះ ឯកឧត្តម កៅ ថាច បានណែនាំឱ្យសហគមន៍ពង្រីកការផលិតស្រូវសែន-ក្រអូបដែលកំពុងមានទីផ្សារ ហើយត្រូវរៀបចំកិច្ចសន្យាកសិកម្ម ជាមួយអ្នកទទួលទិញ ដែលកំពុងធ្វើការទទួលទិញស្រូវពីសហគមន៍ជាច្រើនដោយការទិញនោះធ្វើឡើងតាមតម្លៃទីផ្សារ។

៣ កក្កដា ២០១៨

ពិធីសម្ពោធដាក់ឱ្យដំណើរការឃ្លាំងស្តុកស្រូវ និងឡសម្ងួតនៅខេត្តបាត់ដំបង

នាព្រឹកថ្ងៃអង្គារ ០៦ រោច ខែបឋមសាឍ សំរឹទ្ធិស័ក្ត ពស២៥៦២ ត្រូវនឹងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ឯកឧត្តម ជួ គីមឡេង តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម កៅ ថាច អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទបានអញ្ជើញចូលរួមក្នុង **ពិធីសម្ពោធដាក់ឱ្យដំណើរការឃ្លាំងស្តុកស្រូវទំហំ ២ សែនតោន និងឡសម្ងួតដែលមានសមត្ថភាពសម្ងួតស្រូវ ៣ ពាន់តោន ក្នុងមួយថ្ងៃ** ដែលជាគម្រោងសាងសង់ឃ្លាំងស្តុកស្រូវ និងឡសម្ងួតខ្នាតធំជាងគេនៅព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមគម្រោងវិនិយោគពិសេស ក្នុងទម្រង់ជាបំណុលរបស់រាជរដ្ឋាភិបាលនៃកម្ពុជា ជាមួយ **ក្រុមហ៊ុនធនាគារស្រូវ (កម្ពុជា) ភីអិលស៊ី** តាមរបៀប "សាងសង់-ប្រតិបត្តិការ-និងទូទាត់សំណង" (B.O.P.) ក្នុងតម្លៃសរុបចំនួន **១៥ លានដុល្លារអាមេរិក**។

តាមរយៈបទអន្តរាគមន៍របស់ **ឯកឧត្តម កៅ ថាច អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ** បានធ្វើការរំលឹកជូនដល់បងប្អូនប្រជាពលរដ្ឋជាសហគមន៍ ដែលមានវត្តមានក្នុងពិធីសម្ពោធថា÷

ក្នុងរយៈកាលកន្លងមកជាពិសេស ការធ្លាក់ចុះជាកំហុកនៃតម្លៃស្រូវមិនសមហេតុផលកាលពីឆ្នាំ២០១៦ និងដោយមើលឃើញពីកង្វះឃ្លាំងស្តុកស្រូវ ឡសម្ងួត និងការបង្វិលទុន ក៏ដូចបញ្ហាដែលតែងតែកើតមានដោយសារការផ្គត់ផ្គង់ស្រូវលើសតម្រូវការក្នុងរដូវប្រមូលផលស្រូវជាដើមនិង ដោយមើលឃើញពីការលំបាកដូចនេះ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានដាក់ចេញជាបន្ទាន់នូវគម្រោងអន្តរាគមន៍ពិសេសរបស់រាជរដ្ឋាភិបាល តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ជាប្រតិបត្តិករអនុវត្តគម្រោងពិសេសសាងសង់ឃ្លាំងស្តុកស្រូវ និងឡសម្ងួតស្រូវ នៅក្នុងតំបន់ខេត្តបាត់ដំបង ក្នុងគោលដៅធានាស្ថេរភាពថ្លៃស្រូវ និងលើកកម្ពស់ថ្លៃស្រូវដល់ប្រជាកសិករដើម្បីលើកស្ទួយថ្លៃស្រូវ និងរួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាកសិករ។ ជាលទ្ធផល តាមរយៈយន្តការអន្តរាគមន៍ពិសេស របស់រាជរដ្ឋាភិបាលដែលបានដាក់គម្រោង ឃ្លាំងស្តុក និងឡសម្ងួតស្រូវនេះ នឹងបង្កើនសមត្ថភាពស្តុក និងកិនកែច្នៃស្រូវ-អង្ករ របស់រោងម៉ាស៊ីនកិនស្រូវនៅក្នុងតំបន់ និងបង្កើនលទ្ធភាពនៃការប្រមូលទិញក្នុងបរិមាណច្រើន និងងាយស្រួលក្នុងការគ្រប់គ្រងស្តុកស្រូវនៅក្នុងតំបន់សំខាន់ៗបាន និងធ្វើឱ្យតម្លៃស្រូវរបស់កសិករមានការកើនឡើងគួរកត់សម្គាល់ធៀបនឹងបណ្តាឆ្នាំកន្លងមក។ ជាពិសេសតម្លៃស្រូវសែនក្រអូបបានកើនឡើងដល់ប្រមាណ ១ ២០០ រៀល/គីឡូក្រាម នារដូវប្រមូលផលឆ្នាំ២០១៧-២០១៨ ធៀបនឹងគ្រាដូចគ្នាឆ្នាំមុនប្រមាណ ៩០០ រៀល/គីឡូក្រាម តែប៉ុណ្ណោះ។

៤ កក្កដា ២០១៨

ពិធីសម្ពោធដាក់ឱ្យដំណើរការឃ្លាំងស្តុកស្រូវនិងឡសម្ងួតនៅខេត្តកំពង់ធំ

ព្រឹកថ្ងៃពុធ ៧រោច ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **ឯកឧត្តម កៅ ថាច** អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទបានអញ្ជើញចូលរួមក្នុង **ពិធីសម្ពោធដាក់ឱ្យដំណើរការឃ្លាំងស្តុកស្រូវទំហំ ៥ ម៉ឺនតោន និងឡសម្ងួតដែលមានសមត្ថភាពសម្ងួតស្រូវ ១ ៥០០ តោន ក្នុងមួយថ្ងៃ** ដែលជាគម្រោងសាងសង់ឃ្លាំងស្តុកស្រូវ និងឡសម្ងួតខ្នាតធំជាងគេនៅខេត្តកំពង់ធំ ស្ថិតក្រោមគម្រោងវិនិយោគពិសេសក្នុងទម្រង់ជា បំណុលរបស់រាជរដ្ឋាភិបាលនៃកម្ពុជា ជាមួយ **ក្រុមហ៊ុនអេមុរាយស៍ (ខេមបូឌា) ខូអិលធីឌី** តាមរបៀប “សាងសង់-ប្រតិបត្តិការ-និងទូទាត់សំណង” (B.O.P.) ក្នុងតម្លៃសរុបចំនួន **៥ លានដុល្លារអាមេរិក។**

ក្នុងឱកាសនេះផងដែរ ឯកឧត្តម រស់ សីលវ៉ា បានមានប្រសាសន៍ថា តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ជាប្រតិបត្តិករអនុវត្តគម្រោងពិសេសរបស់រាជរដ្ឋាភិបាល បានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈយន្តការដោះស្រាយបាននូវឃ្លាំងស្តុកស្រូវ ឡសម្ងួតស្រូវ និងផ្តល់ជាទុនបង្វិលរបស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្នុងការផ្តល់ឥណទានដល់រោងម៉ាស៊ីនកិនស្រូវ សម្រាប់ប្រមូលទិញស្រូវនារដូវប្រមូលផល។ យន្តការនេះរក្សាបាននូវតម្លៃសមរម្យដល់បងប្អូនកសិករ និងបំពេញបាននូវបរិមាណស្រូវអង្ករសម្រាប់បម្រើឱ្យការនាំចេញបានគ្រប់គ្រាន់។

ទន្ទឹមនេះ ឯកឧត្តម កៅ ថាច មានភាពជឿជាក់យ៉ាងមុតមាំថា ក្នុងរដូវប្រមូលផលឆ្នាំនេះ តាមរយៈឃ្លាំងស្តុកស្រូវ និងឡសម្ងួតស្រូវខ្នាតធំ ជាសមិទ្ធិផលថ្មីក្នុងទឹកដីខេត្តកំពង់ធំ គឺមានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្រូបស្រូវរបស់បងប្អូនប្រជាកសិករក្នុងតំបន់ និងធានារក្សាបាននូវតម្លៃស្រូវតាមទីផ្សារបាន និងដោះស្រាយបញ្ហាកង្វល់លើការខូចខាតស្រូវរបស់បងប្អូនផងដែរ។

ពិធីសម្ពោធដាក់ឱ្យដំណើរការឃ្លាំងស្តុកស្រូវនិងឡសម្ងួតនៅខេត្តកំពង់ស្ពឺ

ព្រឹកថ្ងៃសុក្រ ៩រោច ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម ជូ វិជិត្ត រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **ឯកឧត្តម កៅ ថាច** អគ្គនាយកនៃ ធនាគារអភិវឌ្ឍន៍ជនបទបានអញ្ជើញចូលរួមក្នុង **ពិធីសម្ពោធដាក់ឱ្យដំណើរការឃ្លាំងស្តុកស្រូវទំហំ ៥ ម៉ឺនតោន និងឡសម្ងួតដែលមានសមត្ថភាពសម្ងួតស្រូវ ១ ៥០០ តោន ក្នុងមួយថ្ងៃ** ដែលជាគម្រោងសាងសង់ឃ្លាំងស្តុកស្រូវ និងឡសម្ងួតខ្នាតធំជាងគេនៅខេត្តកំពង់ស្ពឺ ស្ថិតក្រោមគម្រោងវិនិយោគពិសេសក្នុងទម្រង់ជា បំណុលរបស់រាជរដ្ឋាភិបាលនៃកម្ពុជា ជាមួយ **ក្រុមហ៊ុនខ្មែរហ្វូត គ្រុប ភីអិលស៊ី** តាមរបៀប “សាងសង់-ប្រតិបត្តិការ-និងទូទាត់សំណង” (B.O.P.) ក្នុងតម្លៃសរុបចំនួន **៥ លានដុល្លារអាមេរិក។**

តាមរយៈបទអន្តរាគមន៍របស់ **ឯកឧត្តម កៅ ថាច** អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ បានជម្រាបជូនបងប្អូនសហគមន៍ថា ឃ្លាំងស្តុកស្រូវ និងឡសម្ងួតស្រូវខ្នាតធំនៅក្នុងខេត្តកំពង់ស្ពឺ ដែលត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់នៅព្រឹកនេះ ជាសមិទ្ធិផលថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផ្តល់ជូនប្រជាពលរដ្ឋសម្រាប់តំបន់ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកណ្តាល បន្ទាប់ពីសមិទ្ធិផលឃ្លាំងស្តុកស្រូវ និងឡសម្ងួតស្រូវនៅខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តព្រៃវែង។

១៥ វិច្ឆិកា ២០១៨

ពិធីសម្ពោធទីតាំងសួនដាំបន្លែធម្មជាតិ កម្ពុជា-ជប៉ុន នៅខេត្តកណ្តាល

ព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ **ឯកឧត្តម កៅ ថាច** អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងលោកជំទាវ បានអញ្ជើញចូលរួមសម្ពោធទីតាំង **សួនដាំបន្លែធម្មជាតិ កម្ពុជា-ជប៉ុន** ស្ថិតក្នុងភូមិសាស្ត្រស្រុកកោះធំ ខេត្តកណ្តាល។ សួនបន្លែធម្មជាតិកម្ពុជា-ជប៉ុន ត្រូវបានបង្កើតឡើងដោយមានកិច្ចសហការពីអ្នកជំនាញការមកពីប្រទេសជប៉ុន ដើម្បីដាំដុះបន្លែសរីរាង្គប្រកបដោយគុណភាព មិនមានជាតិគីមី ដោយឈរលើគោលការណ៍ផាសុខភាពប្រជាពលរដ្ឋជាធំ។ កន្លងមកដោយមើលឃើញថាបងប្អូនប្រជាកសិករមួយចំនួនបានដាំដុះបន្លែដោយដាក់សារធាតុគីមីហួសប្រមាណ ដែលទង្វើនេះបានបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋយ៉ាងខ្លាំង។

ដូចនេះដើម្បីផ្លាស់ប្តូរទម្លាប់នៃការដាំដុះបន្លែរបស់កសិករដោយប្រើប្រាស់សារធាតុគីមី និងងាកមកដាំដុះបន្លែដោយប្រើបច្ចេកទេសធម្មជាតិវិញ ឯកឧត្តម កៅ ថាច បានស្នើឱ្យរៀបចំបង្កើតសួនបន្លែធម្មជាតិដាំដុះសាកល្បងនៅក្នុងភូមិសាស្ត្រស្រុកកោះធំ ដោយមានកិច្ចសហការបច្ចេកទេសពីក្រុមការងារមកពីប្រទេសជប៉ុនដោយផ្ទាល់។ ក្នុងករណីសួនបន្លែធម្មជាតិនេះដាំដុះទទួលបានជោគជ័យ ឯកឧត្តម កៅ ថាច នឹងស្នើសុំបន្តធ្វើការពង្រីកការដាំដុះទៅគ្រប់បណ្តាទីតាំងតាមឃុំ ស្រុក ខេត្ត និងតាមបណ្តាតំបន់អ្នកផលិតបន្លែ ដោយចងក្រងប្រជាកសិករអ្នកដាំបន្លែជាសហគមន៍ ហើយក្នុងនោះមានការផ្តល់នូវបច្ចេកទេស ជី ពូជ និងសម្របសម្រួលផ្នែកទីផ្សារជូនដល់បងប្អូនសហគមន៍ផងដែរ។

ឯកឧត្តម កៅ ថាច សង្ឃឹមយ៉ាងមុតមាំថា តាមរយៈវត្តមានសួនបន្លែធម្មជាតិកម្ពុជា-ជប៉ុន នៅក្នុងភូមិសាស្ត្រនេះនឹងធ្វើជាគំរូដល់កសិករ ក្នុងការផ្លាស់ប្តូរជាវិជ្ជមានចំពោះទម្លាប់នៃការដាំដុះដោយប្រើសារធាតុគីមី ដោយជំនួសការដាំដុះដោយធម្មជាតិវិញ ហើយយើងអាចកាត់បន្ថយបាននូវការនាំចូលបន្លែដែលមានសារធាតុគីមីពីបរទេសផងដែរ។

ការចូលរួមការងារមនុស្សធម៌សង្គម

កម្មវិធីសប្បុរសធម៌របស់ធនាគារអភិវឌ្ឍន៍ជនបទ និងសមាគមខ្មែរហាមិលតុន-ភ្នំពេញ ដើម្បីជួយឧបត្ថម្ភដល់អង្គការពន្លឺអនាគត

ឯកឧត្តម កៅ ថាច អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងលោក តឹក យាង ប្រធានសមាគមខ្មែរហាមិលតុន-ភ្នំពេញ ព្រមទាំងសហការី បានចុះសួរសុខទុក្ខសំណេះសំណាលជាមួយក្មួយៗកុមារកំព្រា ក្នុង “**កម្មវិធីសប្បុរសធម៌របស់ធនាគារអភិវឌ្ឍន៍ជនបទ និងនិងសមាគមខ្មែរហាមិលតុន-ភ្នំពេញ ដើម្បីជួយឧបត្ថម្ភដល់អង្គការពន្លឺអនាគត**” នៅមណ្ឌលនៃអង្គការពន្លឺអនាគត ដែលមានទីតាំងស្ថិតនៅភូមិព្រៃល្វា សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឯកឧត្តម កៅ ថាច បានឧបត្ថម្ភអំណោយដល់អង្គការពន្លឺអនាគត រួមមាន អង្ករចំនួន ២ តោន អាវចំនួន ៣០០ អាវ និងថវិកាមួយចំនួន ព្រមទាំងឧបត្ថម្ភសម្ភារៈសិក្សាដល់ក្មួយៗកុមារកំព្រាចំនួន៨០នាក់ ក្នុងម្នាក់ៗទទួលបានសៀវភៅសរសេរ២ក្បាល ប៊ិក២ដើម និងខ្មៅដៃ២ដើម។ ឯកឧត្តម កៅ ថាច ក៏បាន ឧបត្ថម្ភដល់អង្គការពន្លឺអនាគតនូវថវិកាចំនួន១លានរៀលក្នុង១ខែ ក្នុងរយៈពេល១ឆ្នាំផងដែរ។

ក្នុងឱកាសនោះ ឯកឧត្តម កៅ ថាច បានផ្តាំផ្ញើដល់ក្មួយៗកុមារកំព្រាទាំងអស់ឱ្យយកចិត្តទុកដាក់ខិតខំរៀនសូត្រឱ្យបានពូកែ ហើយយ៉ាងហោចណាស់រៀនឱ្យបានចប់វិទ្យាល័យ ត្រូវចេះសាមគ្គីគ្នា ស្រឡាញ់រាប់អានគ្នា ដូចជាបងប្អូនបង្កើត ព្រោះក្មួយៗទាំងអស់គ្នារស់នៅក្រោមដំបូលតែមួយ ទោះបីជាក្មួយៗមិនមានឪពុកម្តាយក៏ដោយ ប៉ុន្តែក្មួយៗមានលោកប្រធានអង្គការនិងលោកគ្រូអ្នកគ្រូនៅក្នុងមណ្ឌលនេះ ដែលជាឪពុកម្តាយបង្កើតរបស់ក្មួយៗក្នុងការចិញ្ចឹមបីបាច់ថែរក្សានិងផ្តល់នូវភាពកក់ក្តៅដល់ក្មួយៗទាំងគ្នា។ ក្រៅពីការសិក្សារៀនសូត្រ ក្មួយៗត្រូវជួយសម្អាតអនាម័យ ថែរក្សាសម្ភារទាំងអស់នៅក្នុងមណ្ឌល ដើម្បីប្រើប្រាស់បានយូរអង្វែង និងធ្វើតែអំពើល្អ ដើម្បីជាគំរូដល់កុមារជំនាន់ក្រោយ។

II. អភិបាលកិច្ចសាជីវកម្ម

១៩ ការគ្រប់គ្រងហានិភ័យនិងការត្រួតពិនិត្យផ្ទៃក្នុង

២១ រចនាសម្ព័ន្ធធនាគារអភិវឌ្ឍន៍ជនបទ

២៣-២៧ ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល

២៨-៣០ ប្រវត្តិរូបសង្ខេបរបស់គណៈគ្រប់គ្រង

ការគ្រប់គ្រងហានិភ័យនិងការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាល

ធនាគារអភិវឌ្ឍន៍ជនបទត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាព ដូចតទៅ÷

១. ឯកឧត្តម រស់ សីលវ៉ា	(ប្រធាន)
២. ឯកឧត្តម សាន វិសាល	(សមាជិក)
៣. ឯកឧត្តម កៅ ថាច	(សមាជិក និងជាអគ្គនាយក)
៤. លោក សរ ចិត្រា	(សមាជិក)
៥. លោក ទាន សុសេរី	(សមាជិក)
៦. លោក អោម សេងបូរ៉ា	(សមាជិក)
៧. លោក ចាន់ សីហា	(សមាជិកតំណាងបុគ្គលិក)

គណៈកម្មការគ្រប់គ្រងហានិភ័យ

គណៈកម្មការគ្រប់គ្រងហានិភ័យគឺជាគណៈកម្មការក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។ គណៈកម្មការនេះមានតួនាទីទទួលខុសត្រូវចំពោះក្រុមប្រឹក្សាភិបាលលើការគ្រប់គ្រងហានិភ័យដូចខាងក្រោម÷

- ពិនិត្យ និងសម្រេចលើយុទ្ធសាស្ត្រគោលនយោបាយ គោលការណ៍ នីតិវិធី និងប៉ារ៉ាមែត្រសមស្របសម្រាប់គ្រប់គ្រងរាល់ហានិភ័យដែលអាចកើតឡើងចំពោះធនាគារ ហើយធ្វើការកែសម្រួលក្នុងករណីចាំបាច់។
- ពិនិត្យទិន្នន័យហានិភ័យដែលរាយការណ៍ដោយថ្នាក់ដឹកនាំប្រតិបត្តិហើយប្រៀបធៀបជាមួយយុទ្ធសាស្ត្រ គោលនយោបាយ គោលការណ៍ នីតិវិធី និងប៉ារ៉ាមែត្រដែលបានកំណត់ដោយធនាគារ។
- ផ្តល់អនុសាសន៍ជូនថ្នាក់ដឹកនាំប្រតិបត្តិនិង ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងបញ្ហាគ្រប់គ្រងហានិភ័យក្នុងករណីចាំបាច់។
- ធានាភាពសមស្របនៃរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធនិងធនធានផ្សេងៗទៀតដែលគាំទ្រការងារគ្រប់គ្រងហានិភ័យ។

គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្មគឺជាគណៈកម្មការឯករាជ្យ ដែលស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។ គណៈកម្មការសវនកម្ម មានតួនាទីពង្រឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងហានិភ័យ ដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃនីតិវិធីធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងនីតិវិធីសវនកម្ម។
- ធានាប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធគ្រប់គ្រងហានិភ័យ។
- អនុម័តផែនការការងារសវនកម្មផ្ទៃក្នុង និងលទ្ធផលនៃការធ្វើសវនកម្មផ្ទៃក្នុងដើម្បីដាក់ជូន ក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច។
- ការធានាភាពត្រឹមត្រូវនៃរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ។

ក្រុមប្រឹក្សាវិន័យ

ក្រុមប្រឹក្សាវិន័យគឺជាគណៈកម្មការពិសេសមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំប្រតិបត្តិ។ គណៈកម្មការនេះមានតួនាទីដូចខាងក្រោម÷

- ពិនិត្យនិងវាយតម្លៃលើសំណើសុំតែងតាំង និងដំឡើងឋានៈ ដោយផ្អែកលើគុណសម្បត្តិ។
- ពិនិត្យអំពីភាពសមស្របនៃកម្រិតប្រាក់បៀវត្ស និងលាភការផ្សេងៗរបស់បុគ្គលិក។
- ពិនិត្យនិងវាយតម្លៃលើការលើកទឹកចិត្ត និង ផ្តល់រង្វាន់ជូនបុគ្គលិក ដោយផ្អែកលើលទ្ធផលការងារវិសេសវិសាល។
- ពិនិត្យនិងវាយតម្លៃលើការដាក់ទណ្ឌកម្មចំពោះបុគ្គលិកដែលមិនគោរពវិន័យ ដូចបានចែងក្នុងលក្ខន្តិកៈបុគ្គលិក។
- ពិនិត្យ និងស៊ើបអង្កេតអំពីករណីខុសឆ្គងរបស់បុគ្គលិកគ្រប់ថ្នាក់ ហើយចាត់វិធានការបើចាំបាច់។

រចនាសម្ព័ន្ធធនាគារអភិវឌ្ឍន៍ជនបទ

រចនាសម្ព័ន្ធ ធនាគារអភិវឌ្ឍន៍ជនបទ កែប្រែលើកទី០៣

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី០៦ ប្រជុំលើកទី១៩ នៅថ្ងៃ២៣ ខែធ្នូ ឆ្នាំ២០១៦

លេខ...០៤៥/១៦ ស.ក.........ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦

រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារ អភិវឌ្ឍន៍ជនបទ



ក្រុមប្រឹក្សាភិបាល

មើលចំពីមុខ (ឈរពីឆ្វេងទៅស្តាំ)

១	២	៣	៤	៥	៦	៧	៨
លោក ទាន សុសេរី	លោក សរ ចិត្រា	លោក អោម សេងបូរ៉ា	ឯកឧត្តម រស់ សីលវ៉ា	ឯកឧត្តម កៅ ថាច	ឯកឧត្តម សាន វិសាល	លោក ចាន់ សីហា	លោក គឹម ផល្លា

ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល

ឯកឧត្តម វង់ សីលវ៉ា
អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ប្រធានក្រុមប្រឹក្សាភិបាល

ឯកឧត្តម វង់ សីលវ៉ា

បច្ចុប្បន្ន ជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាប្រធានក្រុម-ប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ។

ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៨៧ ឯកឧត្តមបានបំពេញការងារជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍នៃ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។ នៅឆ្នាំ១៩៩៣ ឯកឧត្តមបានបំពេញការងារ ជាសាស្ត្រា-ចារ្យ នៅ វិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញនៃក្រសួងអប់រំយុវជន និងកីឡា។

ចាប់តាំងពីឆ្នាំ១៩៩៤ ឯកឧត្តមបំពេញការងារនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។

ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ឯកឧត្តមជានាយករងផែនការគោលនយោបាយសេដ្ឋកិច្ចជាតិនិងហិរញ្ញវត្ថុ និងត្រួតពិនិត្យ។

ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៦ ឯកឧត្តមជានាយកនៃនាយក-ដ្ឋានសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។

ឯកឧត្តម ត្រូវបានតែងតាំងជាអគ្គលេខាធិការរងនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីឯកឧត្តមវិលត្រឡប់មកពីបំពេញការងារជាទីប្រឹក្សានាយកប្រតិបត្តិធនាគារពិភពលោក អំឡុងឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ហើយឯកឧត្តមត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឆ្នាំ២០១៣។

ឯកឧត្តមក៏ជាអ្នករួមចំណែកក្នុងការតាក់តែងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងទាក់ទងការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ។

ឯកឧត្តម ទទួលបានបរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រសង្គម ពីវិទ្យា-ស្ថានគរុកោសល្យប៉េនហ្សា (BA in Social Science from Penzas Institute of Pedagogy) អតីតសហភាពសូវៀតនៅឆ្នាំ១៩៩២។ នៅឆ្នាំ២០០២ ឯកឧត្តមទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកកិច្ចការអន្តរជាតិគ្រប់គ្រងនយោបាយសេដ្ឋកិច្ចពីសាកលវិទ្យាល័យកូឡុមប៊ី ទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក។

ឯកឧត្តម សាន វិសាល
អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្នជាអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជាសមាជិក ក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ។

ពីឆ្នាំ១៩៩០ ដល់ ឆ្នាំ២០០៥ ឯកឧត្តមបានបំពេញការងារជាមន្ត្រីបច្ចេកទេសនៅ នាយកដ្ឋានគ្រឿងយន្តកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងការិយាល័យបមាណីយសំភារៈកសិកម្មនៃក្រសួងកសិកម្ម។

ពី ឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ឯកឧត្តមជាប្រធានមន្ទីរសាលាខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ។

ក្រៅពីបំពេញការងាររដ្ឋ ឯកឧត្តមមានបទពិសោធន៍ការងារជាមួយវិស័យឯកជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផងដែរ ចាប់ពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន ឯកឧត្តមជាអគ្គលេខា-ធិការនៃសហព័ន្ធនិស្សិតបញ្ញវ័ន្តប្រជាធិបតេយ្យកម្ពុជា (ក្រុម២២)។

ឯកឧត្តមទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យានៅឆ្នាំ២០០៥ ហើយ ឯកឧត្តមបានបំពេញវគ្គបណ្តុះបណ្តាលសំខាន់ៗផងដែរ៕

ឯកឧត្តម កៅ ថាច

សមាជិកក្រុមប្រឹក្សាភិបាល

អគ្គនាយក ធនាគារអភិវឌ្ឍន៍ជនបទ

ឯកឧត្តម កៅ ថាច

ត្រូវបានតែងតាំងជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤។

ឯកឧត្តមក៏ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើរដ្ឋលេខាធិការ និងធ្លាប់ជាមជ្ឈត្តករនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ចាប់តាំងពីឆ្នាំ២០០៣។

មុនទទួលតំណែងជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ ឯកឧត្តមធ្លាប់បំពេញការងារជាអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា និង ជាប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុនៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ។ ការងារក្នុងផ្នែកច្បាប់ ឯកឧត្តមធ្លាប់ជាមន្ត្រីច្បាប់នៅក្រសួងយុត្តិធម៌ និងនៅតុលាការផងដែរ។

ឯកឧត្តមជាមន្ត្រីសំខាន់ម្នាក់ក្នុងចំណោមមន្ត្រីដ៏ទៃទៀតដែលបានរៀបចំបង្កើតគណៈកម្មការមូលបត្រកម្ពុជា និងទីផ្សារមូលបត្រនៅកម្ពុជាចាប់ពីដំបូងមក។ បន្ទាប់ពីផ្ទេរទៅបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឯកឧត្តមបានបំពេញការងារជាច្រើនពាក់ព័ន្ធការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលរួមមាន ការចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងជាសមាជិកក្រុមការងារដែលទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងឆ្នាំ២០១១-២០២០។

ក្នុងនាមជាតំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមគឺជាសមាជិកក្រុមការងារក្របខ័ណ្ឌអាស៊ានពាក់ព័ន្ធការអភិវឌ្ឍទីផ្សារទុនដូចជា ACMF, ABMI, CMI, WG-FSL, WG-CAL ជាដើម។

ចំណែកការសិក្សា ឯកឧត្តមទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យ Bond នៅប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០០២ ដែលការសិក្សាផ្តោតលើប្រព័ន្ធច្បាប់ពាណិជ្ជកម្មអន្តរជាតិ ក្របខ័ណ្ឌគតិយុត្ត នៃអង្គការពាណិជ្ជកម្មពិភពលោក ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងបរិញ្ញាប័ត្រនីតិសាស្ត្រនៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅ ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៨។ ក្រៅពីនេះ ឯកឧត្តមបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍទីផ្សារមូលបត្រនៅ ទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក និងវគ្គបណ្តុះបណ្តាលអំពីច្បាប់ហិរញ្ញវត្ថុអន្តរជាតិដោយផ្តោតលើ ច្បាប់នៃធនាគារពិភពលោកមូលនិធិអភិវឌ្ឍន៍អន្តរជាតិ និងធនាគារ សម្រាប់ការទូទាត់អន្តរជាតិនៅទីក្រុងរៀនណាប្រទេសអូទ្រីស ព្រមទាំងវគ្គបណ្តុះបណ្តាលសំខាន់ៗជាច្រើនទៀត៕

លោក សរ ចិត្រា

អគ្គលេខាធិការរង ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្នជាអគ្គលេខាធិការរង ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ហើយជាសមាជិកក្រុមប្រឹក្សាភិបាលធនាគារអភិវឌ្ឍន៍ជនបទ។

លោក សរ ចិត្រា បានបម្រើការងារ និងមានបទពិសោធន៍ជាច្រើន នៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ តាំងពីឆ្នាំ២០០៥ មកម្ល៉េះ ក្នុងនោះគឺ៖

- ខែមិថុនា ឆ្នាំ១៩៩៥ ដល់ខែមេសា ឆ្នាំ១៩៩៩: ជាមន្ត្រីការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- ខែតុលា ឆ្នាំ២០០៥ដល់ខែធ្នូឆ្នាំ២០០៧: ជាអនុប្រធានការិយាល័យផលិតកម្ម នៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
- ខែធ្នូ ឆ្នាំ២០០៧ ដល់ ខែមិថុនា ឆ្នាំ២០១១: ជាប្រធានការិយាល័យផលិតកម្ម នៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
- ខែមិថុនា ឆ្នាំ២០១១ ដល់ខែមីនា ឆ្នាំ២០១៤: ជាអនុប្រធាននាយក-ដ្ឋានផលិតកម្មនិងបសុព្យាបាល
- មីនា ឆ្នាំ២០១៤ ដល់ខែធ្នូ ឆ្នាំ២០១៦: ជាអគ្គលេខាធិការរង ទទួលបន្ទុកនាយកដ្ឋានផែនការនិងស្ថិតិ និងនាយកដ្ឋានកិច្ចការរដ្ឋបាល។

លោក សរ ចិត្រា បានបញ្ចប់ការសិក្សាបណ្ឌិតផ្នែកវិទ្យាសាស្ត្រសត្វ ពីសាកលវិទ្យាល័យអ៊ីវ៉ាតេ ប្រទេសជប៉ុនក្នុងឆ្នាំ២០០៥ និង បានទទួលសញ្ញាបត្រ អនុបណ្ឌិតវិទ្យាសាស្ត្រសត្វ ពីសាកលវិទ្យាល័យ Iwate ប្រទេសជប៉ុនក្នុងឆ្នាំ២០០២៕

លោក ទាន សុសេរី

ជំនួយការខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
អចិន្ត្រៃយ៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី
សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ននេះ ជាជំនួយការខុទ្ទកាល័យឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ហើយជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ។

លោកធ្លាប់បំពេញការងារជាប្រធានផ្នែករដ្ឋបាល និងបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ និងជាប្រធានផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងអប់រំ នៃនាយកដ្ឋានការពារនិងអប់រំក្នុងឆ្នាំ២០០៩នៅអាជ្ញាធរដែនដីជាតិ "គណៈ-រដ្ឋមន្ត្រី" ផងដែរ។

លោក ទាន សុសេរី បានកំពុងបន្តការសិក្សាបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ នៅរាជបណ្ឌិតសភាកម្ពុជា ។

លោក អោម សេងបូរ៉ា

តំណាងអភិបាលឯករាជ្យ

សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្នជាតំណាងអភិបាលឯករាជ្យ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ។

ជាមួយគ្នានេះ បច្ចុប្បន្នលោកក៏ជាអភិបាលឯករាជ្យនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងជាសមាជិកនៃសភាពាណិជ្ជកម្មកម្ពុជាផងដែរ។

ក្រៅពីការបំពេញការងាររដ្ឋ លោកមានមុខតំណែងនិងបទពិសោធន៍ទាំងផ្នែកឯកជន ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ លោកជាអគ្គនាយកប្រតិបត្តិនៃអង្គការ Vision Fund កម្ពុជា។ ពីឆ្នាំ២០១០ មកដល់បច្ចុប្បន្ន លោក គឺជាប្រធានក្រុមហ៊ុន Aplus Counsulting and Aplus School for Professionals និងជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា។ ឆ្នាំ២០១៣ ដល់បច្ចុប្បន្ន លោកជាសមាជិកស្ថាបនិក និងក្រុមប្រឹក្សាភិបាលនៃក្លឹបវិនិយោគិនកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃបណ្តាញចាប់ផ្តើមអាជីវកម្ម។ ឆ្នាំ២០១៤ ដល់បច្ចុប្បន្ន លោកជាអភិបាលឯករាជ្យនៃអង្គការ Teuk Saat 1001 និងជាស្ថាបនិកនិងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Cambodia Empire Group។

លោកបានបញ្ចប់ការសិក្សាសញ្ញាប័ត្រជាន់ខ្ពស់គ្រប់គ្រងអាជីវកម្មនៅសកលវិទ្យាល័យ Preston ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៨ និងបរិញ្ញាប័ត្រគ្រប់គ្រង ជំនាញគណនីពីសាកលវិទ្យាល័យ Maharishi Vedic កម្ពុជា ក្នុងឆ្នាំ១៩៩៨៕

លោក ចាន់ សីហា

តំណាងបុគ្គលិក

សមាជិកក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន គឺជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានឥណទាន និងនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម និងយុទ្ធសាស្ត្រនិងជាសមាជិកក្រុមប្រឹក្សាភិបាលតំណាងបុគ្គលិក នៃធនាគារអភិវឌ្ឍន៍ជនបទ។

លោកបានបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទចាប់ពីខែមករា ឆ្នាំ១៩៩៩ ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវបានតែងតាំងជាអគ្គនាយករងទទួលបន្ទុកនៅខែកក្កដា ឆ្នាំ២០១២។

ពីឆ្នាំ១៩៩១ដល់ឆ្នាំ១៩៩៩លោកបានបម្រើការងារជាអនុប្រធានការិយាល័យគ្រប់គ្រងគណនី ជាប្រធានផ្នែកនៃការិយាល័យសភាផាត់ទាត់ នាយកដ្ឋានប្រតិបត្តិការ និងជាបុគ្គលិកគណនេយ្យនៃនាយកដ្ឋានគណនេយ្យនៃធនាគារជាតិនៃកម្ពុជា។

លោកទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រង ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាប័ត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារនៅទីក្រុងហូជីមិញ ប្រទេសវៀតណាមនៅឆ្នាំ១៩៩១៕

ប្រវត្តិរូបសង្ខេបរបស់គណៈគ្រប់គ្រង

ឯកឧត្តម កៅ ថាច

អគ្គនាយក ធនាគារអភិវឌ្ឍន៍ជនបទ

- ត្រូវបានតែងតាំងជា អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។
- ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើរដ្ឋលេខាធិការ និងធ្លាប់ជាមជ្ឈត្តករនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលចាប់តាំងពីឆ្នាំ ២០០៣។
- ឯកឧត្តមធ្លាប់បំពេញការងារជាអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា និង ជាប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុនៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង ជាមន្ត្រីច្បាប់នៅក្រសួងយុត្តិធម៌ និងនៅតុលាការផងដែរ។
- ជាមន្ត្រីសំខាន់ម្នាក់ក្នុងចំណោមមន្ត្រីដ៏ទៃទៀតបានរៀបចំបង្កើតគណៈកម្មការមូលបត្រកម្ពុជា និងទីផ្សារមូលបត្រនៅកម្ពុជាចាប់ពីដំបូងមក។
- បានចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងជាសមាជិកក្រុមការងារដែលទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ និង ២០១១-២០២០។
- ជាសមាជិកក្រុមការងារក្របខ័ណ្ឌអាស៊ានពាក់ព័ន្ធការអភិវឌ្ឍទីផ្សារទុនដូចជា ACMF, ABMI, CMI, WG-FSL, WG-CAL ជាដើម។

លោក ចាន់ សីហា

អគ្គនាយករង
នៃធនាគារអភិវឌ្ឍន៍ជនបទ

ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានឥណទាន និងនាយកដ្ឋានអភិវឌ្ឍន៍អាជីវកម្ម និងយុទ្ធសាស្ត្រ និងជាសមាជិកក្រុមប្រឹក្សាភិបាលតំណាងបុគ្គលិកនៃធនាគារអភិវឌ្ឍន៍ជនបទ។

លោកបានបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទ ចាប់ពីខែមករា ឆ្នាំ១៩៩៩ ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវបានតែងតាំងជាអគ្គនាយករងនៅខែកក្កដា ឆ្នាំ២០១២។

ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៩ លោកបានបម្រើការងារជាអនុប្រធានការិយាល័យគ្រប់គ្រងគណនី ជាប្រធានផ្នែកនៃការិយាល័យសភាជាត់ទាត់ នាយកដ្ឋានប្រតិបត្តិការ និងជាបុគ្គលិកគណនេយ្យនៃនាយកដ្ឋានគណនេយ្យនៃធនាគារជាតិនៃកម្ពុជា។

លោកទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាប័ត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នៅឆ្នាំ១៩៩១៕

លោក អ៊ុច ចន្ថា

អគ្គនាយករង
នៃធនាគារអភិវឌ្ឍន៍ជនបទ

ជាអគ្គនាយករងទទួលបន្ទុកក្រុមការងារបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ។ លោកបានបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទក្នុងខែសីហា ឆ្នាំ ១៩៩៩ ជាប្រធាននាយកដ្ឋានរដ្ឋបាល នីតិយុត្ត និងជាប្រធានលេខាធិការដ្ឋាន និងត្រូវបានតែងតាំងជាអគ្គនាយករងនៅខែកញ្ញា ឆ្នាំ ២០០៨។

លោកធ្លាប់បានបំពេញការងារជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិជំរុញចលនាភូមិផលិតផល ១មន្ត្រីអគ្គលេខាធិការដ្ឋាននៃ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មន្ត្រីអគ្គលេខាធិការដ្ឋាននៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌នៃទីស្ដីការគណៈរដ្ឋមន្ត្រី និងជាជំនួយការទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកសេដ្ឋកិច្ច។

លោកបានទទួលបរិញ្ញាប័ត្រពីសាកលវិទ្យាល័យភ្នំពេញនៅឆ្នាំ១៩៩១។

លោក ប៉ិច សានី

អគ្គនាយករង
នៃធនាគារអភិវឌ្ឍន៍ជនបទ

ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃធនាគារអភិវឌ្ឍន៍ជនបទ។
លោកបានចូលបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទក្នុងខែមករា ឆ្នាំ២០០១ ជាអនុប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ និងជាប្រធានអង្គភាពគ្រប់គ្រងគម្រោង និងត្រូវបានតែងតាំងជាអគ្គនាយករងនៅខែតុលា ឆ្នាំ២០០៨។

ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ២០០០ លោកបានបម្រើការងារជាមន្ត្រីនៃនាយកដ្ឋានត្រួតពិនិត្យនៅធនាគារជាតិនៃកម្ពុជា និងបន្ទាប់មកបម្រើការងារនៅ Rich Nation Bank មានតួនាទីជាជំនួយការប្រធានសាខា។

លោកបានទទួលបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាប័ត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារនៅទីក្រុងហូជីមិញ ប្រទេសវៀតណាមនៅឆ្នាំ១៩៩១។

លោក ម៉ក់ សុផល

អគ្គនាយករង
នៃធនាគារអភិវឌ្ឍន៍ជនបទ

ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងហានិភ័យ នៃធនាគារអភិវឌ្ឍន៍ជនបទ។

លោកបានចូលបំពេញការងារនៅធនាគារអភិវឌ្ឍន៍ជនបទ ក្នុងខែមករា ឆ្នាំ ១៩៩៩ ជាប្រធាននាយកដ្ឋានឥណទាន និងត្រូវបានតែងតាំងជាអគ្គនាយករង នៃធនាគារអភិវឌ្ឍន៍ជនបទនៅខែមេសា ឆ្នាំ២០១៨។

ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨ លោកបានបម្រើការងារជាមន្ត្រីនៃនាយកដ្ឋានត្រួតពិនិត្យនៅធនាគារជាតិនៃកម្ពុជា និងបម្រើការងារក្រៅ-ម៉ោងនៅធនាគារសន្តិភាពពាណិជ្ជចំកាត់។

លោកបានទទួលបរិញ្ញាប័ត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារនៅទីក្រុងហូជីមិញ ប្រទេសវៀតណាមនៅឆ្នាំ១៩៩៣។

III. របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ

៣៣-៣៦	របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
៣៧	សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាភិបាល
៣៨-៤១	របាយការណ៍របស់សវនករឯករាជ្យ
៤២-៤៣	តារាងតុល្យការ
៤៤	គណនីលទ្ធផល
៤៥	របាយការណ៍ចរន្តមូលនិធិម្ចាស់ភាគហ៊ុន
៤៦	របាយការណ៍ចរន្តសាច់ប្រាក់
៤៧-៨៦	កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍នេះមានផ្នែកមួយនៅខាងក្រោយដែលតំរូវដោយធនាគារជាតិនៃកម្ពុជា ដែលជាផ្នែកដោយឡែកពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (ទំព័រទី I ដល់ទំព័រទី XII) ។

ធនាគារអភិវឌ្ឍន៍ជនបទ
RURAL DEVELOPMENT BANK

លេខ / No : .... ធ.អ.ជ / RDB

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានកិត្តិយសដាក់ជូនពិនិត្យនូវរបាយការណ៍ប្រចាំឆ្នាំ និង របាយការណ៍ហិរញ្ញវត្ថុរបស់ **ធនាគារ អភិវឌ្ឍន៍ ជនបទ** (លំដាប់នេះតទៅហៅកាត់ថា "ធនាគារ") សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018។

ធនាគារអភិវឌ្ឍន៍ជនបទ

ធនាគារអភិវឌ្ឍន៍ជនបទជាស្ថាប័នរបស់រដ្ឋដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យចុះថ្ងៃទី 21 ខែមករា ឆ្នាំ 1998 ក្នុងគោលបំណងបំពេញនូវកង្វះខាតវាងតំរូវការ និង ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុនៅជនបទដើម្បី កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ធនាគារធ្វើប្រតិបត្តិការដោយស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និង ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និង ក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

សកម្មភាពចម្បង

សកម្មភាពធនាគារនៅក្នុងឆ្នាំនេះ ពុំមានការផ្លាស់ប្តូរជាសំខាន់ទៅលើប្រភេទនៃសកម្មភាពចំបងទាំងនោះទេ ពោលគឺធនាគារមានសកម្មភាពក្នុងការផ្តល់ធនធានហិរញ្ញវត្ថុ ដល់ធនាគារពាណិជ្ជកម្ម និងឯកទេស និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលផ្តល់ឥណទាន និងសេវាកម្មគណនីសន្សំដល់គ្រួសារនៅជនបទ និង អាជីវកម្មធុនតូច។ បន្ថែមនឹងនេះ សកម្មភាពរបស់ធនាគារត្រូវបានពង្រីកដោយអនុក្រឹត្យចុះថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 2007 ដោយរាប់បញ្ចូលបន្ថែមនូវការអនុវត្តគំរោងអភិវឌ្ឍន៍តាមសំណើរបស់ដៃគូ ក្នុងកាលៈទេសៈដែលប្រតិបត្តិក រមីក្រូហិរញ្ញវត្ថុពុំអាចអនុវត្តបាន ការផ្តល់ឥណទានដើម្បីអនុវត្តគំរោងពិសេសណាមួយរបស់រាជរដ្ឋាភិបាល ឬ គំរោងពិសេសផ្សេងទៀតដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

លទ្ធផលនៃប្រតិបត្តិការ និង លាភការ

លទ្ធផលប្រចាំឆ្នាំរបស់ធនាគារសំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 មានបង្ហាញនៅក្នុងគណនី លទ្ធផល នៅទំព័រទី 12 ។

ក្រុមប្រឹក្សាភិបាលមិនបានសំរេចប្រកាស ឬបែងចែកភាគលាភ សំរាប់ការិយបរិច្ឆេទនេះទេ ។

ទ្រព្យសកម្ម

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលអោយ ចំនួននៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពមិនត្រឹមត្រូវជំុជាសារវន្តទេ ។

ទុនបំរុង និង សំវិធានធន

ចលនា គណនីទុនបំរុង និងសំវិធានធននៅក្នុងឆ្នាំហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញក្នុងកំណត់សំគាល់លេខ 16 ។

បំណុលជាប់សង្ស័យ និង ពិបាកទារ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា ពួកគេបានចាត់វិធានការទាក់ទងទៅនឹងការលុបចោលបំណុលដែលទារមិនបាន និងការធ្វើសំវិធានធនចំពោះបំណុលដែលជាប់សង្ស័យ និងមានការជឿជាក់ថា រាល់បំណុលដែលដឹងថាមិនអាចទារបានត្រូវបានលុបចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសំរាប់ បំណុលដែលជាប់សង្ស័យ ។

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលអោយចំនួនទឹកប្រាក់ដែលលុបចេញចំពោះបំណុលទារមិនបាន ឬទឹកប្រាក់សំវិធានធនចំពោះបំណុលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មិនគ្រប់គ្រាន់រហូតដល់កំរិតទឹកប្រាក់ធំដុំជាសារវន្តណាមួយនោះទេ។

ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា ដោយឡែកតែឥណទាន បណ្តាទ្រព្យសកម្មចរន្តដែលមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាអោយបានស្មើនឹងតម្លៃជាក់ស្តែងនៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយអោយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានលើទីផ្សារ ។

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើអោយ ប៉ះពាល់ប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពមិនត្រឹមត្រូវធំដុំជាសារវន្តណាមួយឡើយ។

វិធីសាស្ត្រនៃការវាយតម្លៃ

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និង ទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារមានភាពមិនត្រឹមត្រូវ ឬ មិនសមស្របធំដុំជាសារវន្តណាមួយនោះទេ។

ផែនទ្រព្យអកម្មនិងទ្រព្យអកម្មផ្សេងៗទៀត

មកដល់ថ្ងៃចេញរបាយការណ៍នេះ គឺពុំមាន ៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតមានឡើងនៅដំណាច់ការិយបរិច្ឆេទសំរាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយ ឬ

(ខ) ផែនទ្រព្យអកម្មណាមួយកើតមានឡើងចំពោះធនាគារចាប់តាំងពីដំណាច់ការិយបរិច្ឆេទ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ ។

ផែនទ្រព្យអកម្មនិងទ្រព្យអកម្មផ្សេងៗទៀត (តពីទំព័រមុន)

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល គឺពុំមានផែនទ្រព្យអកម្ម ឬ ទ្រព្យអកម្មផ្សេងៗទៀតរបស់ធនាគារដែលត្រូវមានកាតព្វកិច្ចអនុវត្ត ឬ អាចនឹងត្រូវមានកាតព្វកិច្ចអនុវត្តក្នុងរយៈពេល 12 ខែ បន្ទាប់ពីថ្ងៃបញ្ចប់បញ្ជីនៃការិយបរិច្ឆេទ ដែលនឹងមានការប៉ះពាល់ ឬ អាចនឹងមានការប៉ះពាល់យ៉ាងសំខាន់ដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់ ។

ការផ្លាស់ប្តូរនៃហេតុការណ៍

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលនៃធនាគារពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្តាលអោយមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានចំនួនមិនត្រឹមត្រូវធំដុំណាមួយនោះឡើយ ។

ប្រការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ប្រសិទ្ធិភាពហិរញ្ញវត្ថុ របស់ធនាគារក្នុងការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ពុំមានការប៉ះពាល់ធំដុំ ដោយប្រការ ឬ កិច្ចការជំនួញ ឬ ព្រឹត្តិការណ៍ណាមួយដែលមាន លក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានប្រការ កិច្ចការជំនួញ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា បានកើតមានឡើងនៅក្នុងចន្លោះពេលរវាងថ្ងៃបិទបញ្ជីនៃការិយបរិច្ឆេទ និងថ្ងៃចេញរបាយការណ៍នេះ ដែលអាចនាំអោយប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងឆ្នាំដែលបានរាយការណ៍នេះ។

សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរួមមានតំណាងរបស់ក្រសួង និងស្ថាប័នស៊ីវិលដែលមានរាយនាមដូចតទៅ ៖

ឯកឧត្តម រស់ សីលវ៉ា	អភិបាលមិនប្រតិបត្តិ	ប្រធានក្រុមប្រឹក្សាភិបាល
ឯកឧត្តម សាន វិសាល	អភិបាលមិនប្រតិបត្តិ	សមាជិក
ឯកឧត្តម កៅ ថាច	អភិបាលប្រតិបត្តិ	សមាជិក និងជាអគ្គនាយក
លោក សរ ចិត្រា	អភិបាលមិនប្រតិបត្តិ	សមាជិក
លោក ទាន សុសេរី	អភិបាលមិនប្រតិបត្តិ	សមាជិក
លោក អោម សេងបូរ៉ា	អភិបាលមិនប្រតិបត្តិ	សមាជិក
លោក គឹម ផល្លា	អភិបាលមិនប្រតិបត្តិ	សមាជិក
លោក ចាន់ សីហា	អភិបាលប្រតិបត្តិ	សមាជិក

ភាគហ៊ុនកាន់កាប់ដោយសមាជិកក្រុមប្រឹក្សាភិបាល

បណ្តាសមាជិកក្រុមប្រឹក្សាភិបាលដែលនៅបំរើការនាចុងការិយបរិច្ឆេទនេះ មិនមានភាគហ៊ុននៅក្នុងធនាគារទេ។

ទុនបំរុង និង សំវិធានធន

ចលនា គណនីទុនបំរុង និងសំវិធានធននៅក្នុងឆ្នាំហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញក្នុងកំណត់សំគាល់លេខ 16 ។

បំណុលជាប់សង្ស័យ និង ពិបាកទារ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា ពួកគេបានចាត់វិធានការទាក់ទងទៅនឹងការលុបចោលបំណុលដែលទារមិនបាន និងការធ្វើសំវិធានធនចំពោះបំណុលដែលជាប់សង្ស័យ និងមានការជឿជាក់ថា រាល់បំណុលដែលដឹងថាមិនអាចទារបានត្រូវបានលុបចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសំរាប់ បំណុលដែលជាប់សង្ស័យ ។

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលអោយចំនួនទឹកប្រាក់ដែលលុបចេញចំពោះបំណុលទារមិនបាន ឬទឹកប្រាក់សំវិធានធនចំពោះបំណុលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មិនគ្រប់គ្រាន់រហូតដល់កំរិតទឹកប្រាក់ធំដុំជាសារវន្តណាមួយនោះទេ។

ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា ដោយឡែកតែឥណទាន បណ្តាទ្រព្យសកម្មចរន្តដែលមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាអោយបានស្មើនឹងតម្លៃជាក់ស្តែងនៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយអោយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានលើទីផ្សារ ។

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើអោយ ប៉ះពាល់ ប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពមិនត្រឹមត្រូវធំដុំជាសារវន្តណាមួយឡើយ។

វិធីសាស្ត្រនៃការវាយតម្លៃ

មកដល់ថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និង ទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារមានភាពមិនត្រឹមត្រូវ ឬ មិនសមស្របធំដុំជាសារវន្តណាមួយនោះទេ។

ផែនទ្រព្យអកម្មនិងទ្រព្យអកម្មផ្សេងៗទៀត

មកដល់ថ្ងៃចេញរបាយការណ៍នេះ គឺពុំមាន ៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតមានឡើងនៅដំណាច់ការិយបរិច្ឆេទសំរាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយ ឬ

(ខ) ផែនទ្រព្យអកម្មណាមួយកើតមានឡើងចំពោះធនាគារចាប់តាំងពីដំណាច់ការិយបរិច្ឆេទ ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ ។

ធនាគារអភិវឌ្ឍន៍ជនបទ
RURAL DEVELOPMENT BANK
លេខ / No : .... ធ.អ.ជ / RDB

KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាភិបាល

យើងខ្ញុំជាសមាជិកពីររូបនៃថ្នាក់ដឹកនាំ **ធនាគារ អភិវឌ្ឍន៍ ជនបទ** សូមប្រកាសថា តាមយោបល់របស់យើងខ្ញុំ ៖

1) លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារក្នុងការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 មិនមានការប៉ះពាល់ ជាសារវន្ត ដោយប្រការ ឬកិច្ចការជំនួញ ឬព្រឹត្តការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ហើយប្រការ ឬកិច្ចការជំនួញ ឬព្រឹត្តការណ៍ណាមួយនោះក៏ពុំបានកើតមានឡើងនៅក្នុងចន្លោះពេលចាប់ពីថ្ងៃបិទការិយបរិច្ឆេទមកទល់នឹងថ្ងៃចេញរបាយការណ៍នេះទេ ក្រៅពីអ្វីដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ, និង

2) របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលមានភ្ជាប់ ដូចមានចែងនៅទំព័រ 10 ដល់ 54 ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញនូវទិដ្ឋភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងលទ្ធផលហិរញ្ញវត្ថុ និង ស្ថានភាពចរន្តសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃ ខាងលើ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និង ស្តង់ដារគណនេយ្យកម្ពុជា ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

ឯកឧត្តម រស់ សីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

ឯកឧត្តម កៅ ថាច
អគ្គនាយក

ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

សេចក្តីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះ ភាគទុនិក និងក្រុមប្រឹក្សាភិបាល ធនាគារ អភិវឌ្ឍន៍ ជនបទ

មតិលើកលែង

យើងខ្ញុំបានធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ **ធនាគារ អភិវឌ្ឍន៍ ជនបទ** (លំដាប់នេះតទៅហៅកាត់ថា "ធនាគារ") ដែលរួមមាន តារាងតុល្យការ នាការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ព្រមទាំងគណនីលទ្ធផល របាយការណ៍ចរន្តមូលនិធិរបស់ភាគទុនិក របាយការណ៍ចរន្តសាច់ប្រាក់នៃឆ្នាំខាងលើ និងកំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដោយរួមមានគោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ ដូចមានចែងនៅទំព័រ 10 ដល់ 54 ។

យើងខ្ញុំមានមតិថា លើកលែងតែផលប៉ះពាល់ដែលអាចកើតមានលើបញ្ហាដែលបានលើកឡើងក្នុងមូលដ្ឋាននៃមតិលើកលែងខាងក្រោម របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់នេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងប្រសិទ្ធិភាពហិរញ្ញវត្ថុ និងចរន្តសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃខាងលើ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

មូលដ្ឋាននៃមតិលើកលែង

កំណត់សំគាល់លេខ ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ ៖ ចំនួនសរុបនៃការប្រាក់ព្យួរទុក ត្រូវបានរាយការណ៍មាន ចំនួន 1.435.107 ដុល្លារអាមេរិក។ ប្រព័ន្ធឥណទានរបស់ធនាគារមិនអាចបង្កើតនូវព័ត៌មានពេញលេញ ដែលចាំបាច់ដើម្បី គណនាការប្រាក់ព្យួរទុក សម្រាប់ឥណទានមិនដំណើរការ។ ធនាគារមិនអាចផ្តល់នូវយុត្តិកម្មត្រឹមត្រូវ និងពេញលេញ ទាក់ទងនឹងការគណនាការប្រាក់ព្យួរទុកបានឡើយ។ ដូច្នោះហើយ យើងមិនអាចបំពេញចិត្ត របស់យើងចំពោះ ភាពត្រឹមត្រូវ ភាពពេញលេញ និងតម្លៃនៃសមតុល្យការប្រាក់ព្យួរទុក ហើយថាតើការកែតម្រូវ ណាមួយអាចនឹងត្រូវបានកែតម្រូវ សម្រាប់សមតុល្យទាំងនេះនិងធាតុផ្សេងទៀត ក្នុងការរៀបចំតារាងតុល្យការ គណនីលទ្ធផល និង របាយការណ៍ចរន្តសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 តាមរយៈនីតិវិធីសវនកម្មផ្សេងៗ។

យើងខ្ញុំបានធ្វើសវនកម្មគណនេយ្យ ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួល ខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកនៃ ***ការទទួលខុសត្រូវ របស់សវនករសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមាន ឯករាជ្យភាពពីធនាគារ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវដោយវិជ្ជាជីវៈ ដែលពាក់ព័ន្ធទៅនឹងការធ្វើ សវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួល ខុសត្រូវផ្សេងទៀតរបស់យើងខ្ញុំនៅក្នុងវិជ្ជាជីវៈស្របតាមតម្រូវការទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុសមផល ដើម្បីជាមូលដ្ឋានក្នុងការបញ្ចេញមតិ លើកលែងរបស់យើងខ្ញុំ។

សេចក្តីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះ
ភាគទុនិក និងក្រុមប្រឹក្សាភិបាល ធនាគារ អភិវឌ្ឍន៍ ជនបទ (តពីទំព័រមុន)

ព័ត៌មានផ្សេងទៀត

ថ្នាក់ដឹកនាំជាអ្នកទទួលខុសត្រូវចំពោះព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងទៀតដែលទទួលបាននៅកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ គឺជាព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដូចមានចែងនៅទំព័រទី 1 ដល់ទី 5 ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សវនករ ទេ។

មតិរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់លើព័ត៌មានផ្សេងទៀតទេ ហើយយើងខ្ញុំមិនបង្ហាញ ពីការសន្និដ្ឋានលើការធានាណាមួយឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងទៀត ហើយធ្វើការពិចារណាថាតើព័ត៌មានផ្សេងទៀត មានលក្ខណៈមិនសមស្របជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬបើមិនដូច្នោះទេ ថាតើវាទំនងជាមាននូវកំហុសឆ្គងជាសារវន្ត។ ប្រសិនបើផ្អែកលើការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថាព័ត៌មាន ផ្សេងទៀតនេះមាននូវ ព័ត៌មានខុសឆ្គងសំខាន់ៗ យើងខ្ញុំត្រូវរាយការណ៍អំពីករណីនេះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នោះទេ។

ការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

ថ្នាក់ដឹកនាំជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយយោងទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងជាអ្នកទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយដែលចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលគ្មានកំហុសឆ្គងជាសារវន្ត (ដូចជាកំហុសឆ្គងដោយសារការក្លែងបន្លំ ឬ ការភាន់ច្រឡំ) ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ថ្នាក់ដឹកនាំទទួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម បង្ហាញតាមការពាក់ព័ន្ធ នូវករណីដែលទាក់ទងទៅនឹងនិរន្តរភាព នៃដំណើរការអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លើកលែងតែថ្នាក់ដឹកនាំមានបំណង ដើម្បីជម្រះបញ្ជីធនាគារ ឬដើម្បីបញ្ឈប់ប្រតិបត្តិការអាជីវកម្ម ឬមិនមានជម្រើសណាផ្សេងពីនេះ ប៉ុន្តែត្រូវធ្វើដូច្នេះ។

ថ្នាក់ដឹកនាំផ្នែកអភិបាលកិច្ចទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

(តទៅទំព័របន្ទាប់)

របាយការណ៍របស់សវនករឯករាជ្យជូនចំពោះ
ភាគទុនិក និងក្រុមប្រឹក្សាភិបាល ធនាគារ អតិថិខ្សែន៍ ជនបទ (តពីទំព័រមុន)

ការទទួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺដើម្បីទទួលបានការធានាដោយសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូល ពុំមានកំហុសឆ្គងជាសារវន្ត (ដូចជាកំហុសឆ្គងដោយសារការក្លែងបន្លំ ឬ ការភាន់ច្រឡំ) និងដើម្បីចេញ របាយការណ៍សវនករមួយដែលរួមបញ្ចូលទាំងមតិយោបល់របស់យើងខ្ញុំ ។ ការធានាដោយសមហេតុផល គឺជាការធានាដែលមានកម្រិតខ្ពស់ ប៉ុន្តែមិនមែនជាការធានាមួយដែលថា សវនកម្មធ្វើឡើងស្របតាមស្តង់ដារ សវនកម្មអន្តរជាតិនៃកម្ពុជា តែងតែរកឃើញកំហុសឆ្គងជាសារវន្តណាមួយនៅពេលដែលវាកើតឡើង ឡើយ។ កំហុសឆ្គងអាចកើតឡើងពីការបន្លំ ឬភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើ កំហុសឆ្គងមួយ ឬកំហុសឆ្គងជារួម ពួកវាអាចនឹងត្រូវបានគេរំពឹងដោយសមរម្យថា នឹងមានឥទ្ធិពលលើការសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំធ្វើការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាមន្ទិលជាគុនិយមវិជ្ជាជីវៈ នៅក្នុងការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

ក) ធ្វើការកំណត់អត្តសញ្ញាណនិងវាយតម្លៃហានិភ័យ នៃភាពមិនត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំ និងធ្វើរៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិរបស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងសំខាន់ៗ ដែលបណ្តាល មកពីការក្លែងបន្លំ គឺខ្ពស់ជាងកំហុសនៃការភាន់ច្រឡំ ដោយសារកំហុសឆ្គងនៃការក្លែងបន្លំអាចពាក់ព័ន្ធ នឹងការឃុបឃិតការក្លែងបន្លំ ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការមិនធ្វើតាមការ ត្រួតពិនិត្យផ្ទៃក្នុង។

ខ) ទទួលបានការយល់ដឹងអំពីការត្រួតពិនិត្យផ្ទៃក្នុងទាក់ទងនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែល សមស្របតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃការ ត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។

គ) ធ្វើការវាយតម្លៃភាពត្រឹមត្រូវនៃគោលនយោបាយគណនេយ្យដែលបានប្រើ និងភាពសមហេតុផលនៃការប៉ាន់ប្រមាណគណនេយ្យ ប្រសិនបើមាន និងការបង្ហាញពាក់ព័ន្ធដែលធ្វើឡើងដោយថ្នាក់ដឹកនាំ ។

(តទៅទំព័របន្ទាប់)

សេចក្តីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះ
ភាគទុនិក និងក្រុមប្រឹក្សាភិបាល ធនាគារ អភិវឌ្ឍន៍ ជនបទ (តពីទំព័រមុន)

ការទទួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ) ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគ្រឹះនិរន្តរភាពអាជីវកម្ម នៃការចុះបញ្ជីគណនេយ្យរបស់ថ្នាក់ដឹកនាំ ដោយផ្អែកលើភស្តុតាងសវនកម្មដែលបានទទួល ថាតើភាពមិនប្រាកដប្រជាទាក់ទង នឹងព្រឹត្តការណ៍ ឬលក្ខខណ្ឌ ដែលអាចបង្កឱ្យមានការសង្ស័យយ៉ាងធ្ងន់ធ្ងរលើសមត្ថភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនប្រាកដប្រជា តម្រូវឲ្យយើងខ្ញុំទាញការចាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ចំពោះការបង្ហាញព័ត៌មានដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការបង្ហាញបែបនេះមិនគ្រប់គ្រាន់ យើងខ្ញុំត្រូវតែធ្វើការកែប្រែ មតិរបស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ កាលបរិច្ឆេទនៃរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌ នាពេលអនាគត អាចបណ្តាលឱ្យធនាគារផ្អាកប្រតិបត្តិការអាជីវកម្ម ។

ង) ធ្វើការវាយតម្លៃ ការបង្ហាញជាទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មាន និងថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញប្រតិបត្តិការ និងព្រឹត្តិការណ៍សំខាន់ៗ ក្នុងលក្ខណៈដែលសម្រេចបាននូវការបង្ហាញដោយសមស្រប ។

យើងខ្ញុំធ្វើការទំនាក់ទំនងជាមួយថ្នាក់ដឹកនាំផ្នែកអភិបាលកិច្ចរបស់ធនាគារ អំពីបញ្ហាផ្សេងៗ ដូចជា វិសាលភាព និងពេលវេលាសវនកម្មដែលបានគ្រោងទុក និងកំហុសឆ្គងសំខាន់ៗដែលរកឃើញ ដោយរួមមានកង្វះខាត សំខាន់ៗនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលយើងកំណត់បានក្នុងអំឡុងពេលធ្វើសវនកម្ម។

ក្នុងនាមម៉ូរីសុន កាក់ និង អាសូស្សេ

ម៉ូរីសុន កាក់ និង អាសូស្សេ
ក្រុមហ៊ុនគណនេយ្យជំនាញ និង សវនកម្មឯករាជ្យ

មាស សត្និសម
ភាគទុនិកថ្នាក់ដឹកនាំ
ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

No27, Street 440, Sangkat Tuol Tumpung I, Khan Chamcarmon, Phnom Penh, Cambodia
Tel: +855 23218994 (3 Lines) - Fax: +855 23218993 - Email:mka.audit@morisonkak.com
Email:mka.management@morisonkak.com - Website: www.morisonkak.com

Morison KSi
Independent member

ធនាគារ អភិវឌ្ឍន៍ ជនបទ

តារាងតុល្យការ
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	កំណត់សំគាល់	2018 ដុល្លាអាមេរិក	2018 ពាន់រៀល	2017 ដុល្លាអាមេរិក
ទ្រព្យសកម្ម				
សាច់ប្រាក់	4	1,767,588	7,102,169	2,181,446
សមតុល្យនៅធនាគារនានា	5	901,239	3,621,178	5,015,713
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	6	14,568,845	58,537,619	29,570,190
ឥណទាន និងបុរេប្រទាន- សុទ្ធ	7	152,810,766	613,993,658	117,301,679
អចលនទ្រព្យបានរឹបអូស	8	2,875,934	11,555,503	1,158,384
ទ្រព្យសកម្មផ្សេងទៀត	9	2,472,939	9,936,269	1,332,772
ទ្រព្យសកម្មអរូបី	10	11,964	48,071	18,785
ទ្រព្យ និងបរិក្ខារ	11	2,872,030	11,539,817	956,392
សរុបទ្រព្យសកម្ម		**178,281,305**	**716,334,284**	**157,535,361**
ទ្រព្យអកម្ម និង ដើមទុន				
ទ្រព្យអកម្ម				
ប្រាក់បញ្ញើរបស់អតិថិជន	12	3,446,575	13,848,338	2,310,999
ប្រាក់បញ្ញើរបស់ធនាគារនានា	13	24,769	99,522	50,462
ប្រាក់កម្ចី	14	125,844,097	505,641,582	111,758,308
ទ្រព្យអកម្មផ្សេងៗ	15	3,718,082	14,939,254	1,518,773
សំវិធានធនលើពន្ធ	23	661,185	2,656,641	137,647
សរុបទ្រព្យអកម្ម		**133,694,708**	**537,185,337**	**115,776,189**

(តទៅទំព័របន្ទាប់)

ធនាគារ អភិវឌ្ឍន៍ ជនបទ

តារាងតុល្យការ
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 (តពីទំព័រមុន)

	កំណត់សំគាល់	2018 ដុល្លារអាមេរិក	2018 ពាន់រៀល	2017 ដុល្លារអាមេរិក
ដើមទុន				
ដើមទុន	16	24,962,757	100,300,358	22,035,837
ដើមទុនបន្ថែម	16	7,955,048	31,963,383	10,700,928
មូលធនបំរុង	16	899,072	3,612,471	816,974
អនុបំណុល	17	1,044,084	4,195,130	1,044,084
លទ្ធផលបង្គរ		9,725,636	39,077,605	7,161,349
សរុបដើមទុន		**44,586,597**	**179,148,947**	**41,759,172**
សរុបទ្រព្យអកម្ម និង ដើមទុន		**178,281,305**	**716,334,284**	**157,535,361**

អនុញ្ញាតអោយចេញផ្សព្វផ្សាយ និងចុះហត្ថលេខាក្នុងនាមថ្នាក់ដឹកនាំរបស់ធនាគារ

ឯកឧត្តម រស់ សីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

ឯកឧត្តម កៅ ថាច
អគ្គនាយក

ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

គណនីលទ្ធផល
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	កំណត់សំគាល់	2018 ដុល្លារអាមេរិក	2018 ពាន់រៀល	2017 ដុល្លារអាមេរិក
ចំណូលពីការប្រាក់	18	8,317,964	33,421,579	5,631,458
ចំណាយការប្រាក់	19	(619,100)	(2,487,544)	(598,494)
ចំណូលពីការប្រាក់សុទ្ធ		**7,698,864**	**30,934,035**	**5,032,964**
ចំណូលពីប្រតិបត្តិការផ្សេងៗ	20	1,073,187	4,312,065	956,325
ប្រាក់បៀវត្សរ៍ និងចំណាយផ្សេងៗលើបុគ្គលិក	21	(1,883,439)	(7,567,658)	(1,593,473)
ចំណាយរំលស់		(209,005)	(839,782)	(178,461)
ចំណាយទូទៅ និងរដ្ឋបាល	22	(1,790,605)	(7,194,651)	(1,417,440)
ប្រាក់ចំណេញពីប្រតិបត្តិការមុនសំវិធានធន		**4,889,002**	**19,644,009**	**2,799,915**
សំវិធានធនសំរាប់ឥណទានអាចបាត់បង់	7	(1,535,087)	(6,167,980)	(1,646,827)
លទ្ធផលមុនបង់ពន្ធ		**3,353,915**	**13,476,029**	**1,153,088**
ចំណាយបង់ពន្ធ	23	(789,628)	(3,172,725)	(199,834)
លទ្ធផលក្រោយបង់ពន្ធ		**2,564,287**	**10,303,304**	**953,254**

អនុញ្ញាតអោយចេញផ្សព្វផ្សាយ និងចុះហត្ថលេខាក្នុងនាមថ្នាក់ដឹកនាំរបស់ធនាគារ

ឯកឧត្តម រស់ សីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល
ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

ឯកឧត្តម កៅ ថាច
អគ្គនាយក
ថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019

កំណត់សំគាល់ដែលមានភ្ជាប់នៅទំព័រទី 15 ដល់ 54 ត្រូវអានជាមួយរបាយការណ៍នេះ។

ធនាគារ អភិវឌ្ឍន៍ ជនបទ

របាយការណ៍បម្រែបម្រួលមូលនិធិម្ចាស់ភាគហ៊ុន
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	ដើមទុន ដុល្លារអាមេរិក	ដើមទុនបន្ថែម ដុល្លារអាមេរិក	មូលធនបម្រុង ដុល្លារអាមេរិក	អនុបំណុល ដុល្លារអាមេរិក	លទ្ធផលបង្គរ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
សមតុល្យនៅថ្ងៃទី 1 មករា ឆ្នាំ 2017	20,475,890	9,319,136	564,192	1,044,084	6,208,095	37,611,397
ផ្ទេរទៅដើមទុន	1,559,947	(1,559,947)	-	-	-	-
ការសងត្រឡប់ប្រាក់ដើមពីការកាត់បន្ថយដើមទុនតាមរយៈការផ្ទេរតំណទាន មិនដំណើរការ (មើលកំណត់សំគាល់ 16)	-	2,941,739	-	-	-	2,941,739
ការសងត្រឡប់ការប្រាក់ពីការកាត់បន្ថយដើមទុនតាមរយៈការផ្ទេរតំណទាន មិនដំណើរការ (មើលកំណត់សំគាល់ 16)	-	-	252,782	-	-	252,782
លទ្ធផលនៃការិយបរិច្ឆេទ	-	-	-	-	953,254	953,254
សមតុល្យនៅថ្ងៃទី 31 ធ្នូ ឆ្នាំ 2017	**22,035,837**	**10,700,928**	**816,974**	**1,044,084**	**7,161,349**	**41,759,172**
សមតុល្យនៅថ្ងៃទី 1 មករា ឆ្នាំ 2018	22,035,837	10,700,928	816,974	1,044,084	7,161,349	41,759,172
ផ្ទេរទៅដើមទុន	2,926,920	(2,926,920)	-	-	-	-
ការសងត្រឡប់ប្រាក់ដើមពីការកាត់បន្ថយដើមទុនតាមរយៈការផ្ទេរតំណទាន មិនដំណើរការ (មើលកំណត់សំគាល់ 16)	-	181,040	-	-	-	181,040
ការសងត្រឡប់ការប្រាក់ពីការកាត់បន្ថយដើមទុនតាមរយៈការផ្ទេរតំណទាន មិនដំណើរការ (មើលកំណត់សំគាល់ 16)	-	-	82,098	-	-	82,098
លទ្ធផលនៃការិយបរិច្ឆេទ	-	-	-	-	2,564,287	2,564,287
សមតុល្យនៅថ្ងៃទី 31 ធ្នូ ឆ្នាំ 2018	**24,962,757**	**7,955,048**	**899,072**	**1,044,084**	**9,725,636**	**44,586,597**
សមតុល្យនៅថ្ងៃទី 31 ធ្នូ ឆ្នាំ 2018 (ពាន់រៀល)	***100,300,358***	***31,963,383***	***3,612,471***	***4,195,130***	***39,077,605***	***179,148,947***

កំណត់សំគាល់ដែលមានភ្ជាប់នៅទំព័រទី 15 ដល់ 54 ត្រូវអានជាមួយរបាយការណ៍នេះ។

ធនាគារ អភិវឌ្ឍន៍ ជនបទ

របាយការណ៍ចរន្តសាច់ប្រាក់
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

	2018 ដុល្លាអាមេរិក	2018 ពាន់រៀល	2017 ដុល្លាអាមេរិក
ចរន្តសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ			
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ (កំណត់សំគាល់ 24)	**(31,611,937)**	**(127,016,763)**	**(47,833,550)**
ចរន្តសាច់ប្រាក់ពីសកម្មភាពវិនិយោគ			
ការទិញអចលនទ្រព្យ (កំណត់សំគាល់ 11)	(2,114,475)	(8,495,961)	(301,441)
សាច់ប្រាក់ទទួលបានពីការលក់អចលនទ្រព្យ	-	-	2,429
ការទិញទ្រព្យសកម្មអរូបី (កំណត់សំគាល់ 10)	(3,347)	(13,448)	(4,677)
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ	**(2,117,822)**	**(8,509,409)**	**(303,689)**
ចរន្តសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ			
ការបង់សងប្រាក់កម្ចី	(2,061,668)	(8,283,782)	(7,758,975)
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី	15,800,000	63,484,400	59,487,870
សាច់ប្រាក់ទទួលបានពីការសងត្រឡប់ការប្រាក់ពីការកាត់បន្ថយដើមទុនតាមរយៈការផ្ទេរឥណទាន មិនដំណើរការ (កំណត់សំគាល់ 16)	82,098	329,870	252,782
សាច់ប្រាក់ទទួលបានពីការសងត្រឡប់ប្រាក់ដើមពីការកាត់បន្ថយដើមទុនតាមរយៈការផ្ទេរ ឥណទាន មិនដំណើរការ (កំណត់សំគាល់ 16)	181,040	727,419	2,941,739
សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញវត្ថុ	**14,001,470**	**56,257,907**	**25,006,316**
បំរែបំរួលសាច់ប្រាក់ និងសាច់ប្រាក់សមមូល	**(19,728,289)**	**(79,268,265)**	**6,786,177**
សាច់ប្រាក់ និងសាច់ប្រាក់សមមូល ៖			
នៅដើមការិយបរិច្ឆេទ	35,122,075	141,120,497	28,335,898
នៅចុងការិយបរិច្ឆេទ	**15,393,786**	**61,852,232**	**35,122,075**
តំណាងដោយ ៖			
សាច់ប្រាក់ (កំណត់សំគាល់ 4)	1,767,588	7,102,169	2,181,446
សមតុល្យជាមួយធនាគារក្នុងស្រុក (កំណត់សំគាល់ 5)	901,239	3,621,178	5,015,713
សមតុល្យជាមួយធនាគារកណ្តាល (កំណត់សំគាល់ 6)	12,724,959	51,128,885	27,924,916
	15,393,786	**61,852,232**	**35,122,075**

កំណត់សំគាល់ដែលមានភ្ជាប់នៅទំព័រទី 15 ដល់ 54 ត្រូវអានជាមួយរបាយការណ៍នេះ។

ធនាគារ អភិវឌ្ឍន៍ ជនបទ

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

1. អំពីធនាគារ

ធនាគារអភិវឌ្ឍន៍ជនបទ ជាសហគ្រាសរដ្ឋដែលបានបង្កើតឡើងដោយអនុក្រិត្យចុះថ្ងៃទី 21 ខែ មករា ឆ្នាំ 1998 ក្នុងគោលបំណងលើកស្ទួយការអភិវឌ្ឍកសិកម្ម និងជនបទ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរបស់ប្រជាជននៅជនបទ ។

ធនាគារចាប់ផ្តើមធ្វើប្រតិបត្តិការអាជីវកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co. 3942 et/1998 ចេញដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 12 ខែឧសភា ឆ្នាំ 1998។ ធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា សម្រាប់ប្រតិបត្តិជាធនាគារឯកទេស មានសុពលភាពអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 15 ខែ មិថុនា ឆ្នាំ 2007។

ធនាគារមានសិទ្ធិផ្តល់ឥណទានក្រោមអាជ្ញាប័ណ្ណធនាគារឯកទេស និងធ្វើប្រតិបត្តិការហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានអនុញ្ញាតអោយចេញផ្សព្វផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី 24 ខែ មេសា ឆ្នាំ 2019 ។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ

គោលការណ៍គណនេយ្យជាចំបងត្រូវបានអនុវត្តដោយធនាគារ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម ។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តយ៉ាងទៀងទាត់ចំពោះរាល់ឆ្នាំដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

2.1 មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងតាមសន្មតិកម្មតម្លៃដើម ដោយអនុលោមទៅតាមបទបញ្ញត្តិទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា និងដោយផ្អែកទៅលើស្តង់ដារគណនេយ្យកម្ពុជា។ គោលការណ៍ទាំងនេះតំរូវអោយវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ដោយប្រើតម្លៃយោងដោយមានការកាត់បន្ថយសំវិធានធនសំរាប់ការថយចុះតម្លៃ។ វិធាននេះមានលក្ខណៈខុសពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលតំរូវឱ្យវាស់វែងឥណទាន និងគណនីត្រូវទទួល តាមថ្លៃដើមរំលស់ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធិភាព ចំពោះរាល់លំអៀងរវាងតម្លៃដើមគ្រា និងតម្លៃដល់កាលកំណត់ ដោយកាត់បន្ថយសំវិធានធនសំរាប់ការចុះតម្លៃ ឬការប្រមូល ឥណទានមកវិញមិនបាន។

ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា ដែលមានការកែតំរូវដោយគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា តំរូវអោយប្រើការប៉ាន់ប្រមាណយ៉ាងប្រសើរ និងការសន្មត់ដោយសមហេតុផល ដែលមានឥទ្ធិពលលើការរាយការណ៍តួលេខនៃរបាយការណ៍ហិរញ្ញវត្ថុនៅដំណាច់ការិយបរិច្ឆេទ និងកំណត់សំគាល់។ ការប៉ាន់ប្រមាណទាំងនេះមានមូលដ្ឋានលើព័ត៌មានច្បាស់លាស់ដែលមានស្រាប់ និងការយល់ដឹងរបស់ថ្នាក់ដឹកនាំលើព្រឹត្តិការណ៏ និងសកម្មភាពបច្ចុប្បន្ន ។ ដូច្នេះលទ្ធផលជាក់ស្តែងចុងក្រោយអាចមានភាពខុសគ្នាពីការប៉ាន់ប្រមាណទាំងនោះ។

2. គោលការណ៍គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.1 មូលដ្ឋាននៃការរៀបចំ (តពីទំព័រមុន)

របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់ ត្រូវបានរៀបចំឡើងសម្រាប់រង្វង់សមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយពុំមានគោលបំណងធ្វើការបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុនិងស្ថានភាពចរន្តសាច់ប្រាក់ ដោយអនុលោមទៅតាមគោលការណ៍គណនេយ្យ និងការអនុវត្តគណនេយ្យ ដែលទទួលស្គាល់ជាទូទៅនៅក្រៅប្រទេស និងរង្វង់សមត្ថកិច្ចដោយឡែកពីប្រទេសកម្ពុជាទេ។

2.2 ក្របខណ្ឌស្តង់ដារគណនេយ្យថ្មី

នៅថ្ងៃទី 28 ខែ សីហា ឆ្នាំ 2009 ក្រុមប្រឹក្សាជាតិគណនេយ្យ ដោយផ្អែកតាមប្រកាសលេខ 068 សហវ-ប្រក ចុះថ្ងៃទី 8 ខែ មករា ឆ្នាំ 2009 របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសដាក់អោយប្រើប្រាស់នូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិទាំងមូល។ ស្ថាប័នដែលមានការទទួលខុសត្រូវជាសាធារណៈត្រូវតែរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយយោងតាមស្តង់ដារ CIFRS សំរាប់ដើមការិយបរិច្ឆេទ ឬបន្ទាប់ពីការិយបរិច្ឆេទថ្ងៃទី 1 ខែ មករា ឆ្នាំ 2012។

នៅថ្ងៃទី 30 ខែ កក្កដា ឆ្នាំ 2012 ក្រុមប្រឹក្សាជាតិគណនេយ្យ បានជូនដំណឹងដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ អំពីការពន្យារការអនុវត្ត CIFRS រហូតដល់ការិយបច្ឆេទចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី 01 ខែ មករា ឆ្នាំ 2017។

នៅថ្ងៃទី 20 ខែតុលា ឆ្នាំ 2016 សមាគមធនាគារនៅកម្ពុជា (ហៅកាត់ថា "ABC") ដោយលើកឡើងពីការមិនបានត្រៀមខ្លួនរួចរាល់របស់ធនាគារភាគច្រើនក្នុងការអនុវត្ត CIFRS បានធ្វើសំណើទៅធនាគារជាតិនៃកម្ពុជា សុំពន្យាពេលការអនុវត្តស្តង់ដារ CIFRS សម្រាប់រយៈពេលបីឆ្នាំទៀត រហូតដល់ឆ្នាំ 2019។ ដោយផ្អែកលើសំណើនេះ ធនាគារជាតិនៃកម្ពុជាបានស្នើ នៅថ្ងៃទី 16 ខែ វិច្ឆិកា ឆ្នាំ 2015 ទៅក្រុមប្រឹក្សាជាតិគណនេយ្យ ដើម្បីពន្យាពេលការអនុវត្តស្តង់ដារ CIFRS រហូតដល់ឆ្នាំ 2019 ដោយមានការអនុញ្ញាត្តិអោយប្រើប្រាស់មុនបាន។ ក្រុមប្រឹក្សាជាតិគណនេយ្យ បានចេញសេចក្តីប្រកាសមួយចុះថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2016 បានយល់ព្រម ពន្យាពេលការអនុវត្តន៍ CIFRS រហូតដល់ឆ្នាំ 2019 ។

ការដាក់អោយប្រើប្រាស់នូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សំរាប់របាយការណ៍ហិរញ្ញវត្ថុដំបូងនៅការិយបរិច្ឆេទ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2019 នឹងមានផលប៉ះពាល់ជាសារវន្ត ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ ធនាគារនឹងវាយតំលៃពីផលប៉ះពាល់ នៃការដាក់អោយប្រើប្រាស់នូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាដំបូង ហើយការអនុវត្តស្តង់ដារនេះនឹងត្រូវកែប្រែជាចាំបាច់ក្នុងករណីដែលកើតឡើង ។

2.3 ការបកស្រាយរូបិយប័ណ្ណបរទេស

(ក) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបង្ហាញ

ធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើរូបិយប័ណ្ណចំនួនពីរគឺ ប្រាក់រៀល និងប្រាក់ដុល្លាអាមេរិក។ អ្នកគ្រប់គ្រងក៏បានកំណត់ប្រាក់ដុល្លាអាមេរិក ជារូបិយប័ណ្ណមុខងារ

2.8 ប្រាក់បញ្ញើជាមួយធនាគារ

ប្រាក់បញ្ញើ ជាមួយធនាគារត្រូវបានកំណត់តាមថ្លៃដើមដោយដកសំវិធានធនលើចំនួនមិនអាចប្រមូលបាន ។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.9 ប្រាក់តំកល់តាមច្បាប់នៅធនាគារជាតិ

ប្រាក់តំកល់តាមច្បាប់ គឺប្រាក់តំកល់នៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ធនាគារត្រូវតំកល់ប្រាក់លើដើមទុន និង លើប្រាក់បញ្ញើ ស្មើនឹងភាគរយដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តំកល់តាមច្បាប់មិនអាចយកមកប្រើប្រាស់សំរាប់ប្រតិបត្តិការប្រចាំថ្ងៃទេ ហើយពុំត្រូវបានចាត់ទុកជាចំណែកនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល ក្នុងការគណនារបាយការណ៍ចរន្តសាច់ប្រាក់ដែរ។

2.10 ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាននៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ដោយដកចេញចំនួនទាំងឡាយណាដែលបានលុបចោល និងសំវិធានធនជាក់លាក់ និងសំវិធានធនទូទៅ ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់និង ជាប់សង្ស័យត្រូវបានវាយតម្លៃដោយអ្នកគ្រប់គ្រងជារៀងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយ ដែលត្រូវបានពិចារណាក្នុងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំឥណទាន បទពិសោធនៃការខាតបង់កន្លងមក លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថានភាពជាក់ស្តែង នៃឥណទានធៀបនឹងលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យា ។

2.11 សំវិធានធនលើឥណទាន និងបុរេប្រទាន

ធនាគារបានធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដោយអនុលោមតាមតម្រូវការចុងក្រោយរបស់ប្រកាសលេខ ធ7-017-344 ចុះថ្ងៃទី 01 ខែ ធ្នូ ឆ្នាំ 2017 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ចេញដោយធនាគារកណ្តាល។ ប្រកាសនេះតម្រូវឲ្យធនាគារ ទាំងឡាយធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីរបស់ខ្លួនយ៉ាងហោចប្រាំប្រភេទ លើកលែងតែមានព័ត៌មានផ្សេងបញ្ជាក់ពីស្ថានភាពអាក្រក់ជាងនេះ។

សំវិធានធនលើឥណទានត្រូវបានធ្វើឡើងចំពោះហានិភ័យជាក់លាក់លើឥណទាននីមួយៗ ដែលត្រូវបានវាយតំលៃ និងចាត់ថ្នាក់ជា ឥណទានធម្មតា ឃ្លាំមើល ក្រោមស្តង់ដារ ជាប់សង្ស័យ និងបាត់បង់ ។

សេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាតំរូវអោយមានការចាត់ថ្នាក់ និង កំរិតសំវិធានធនដោយផ្អែកទៅលើរយៈពេលហួសកាលកំណត់សងដូចតទៅ ៖

2. គោលការណ៍ គណនេយ្យសំខាន់ៗ (តពីទំព័រមុន)

2.11 សំវិធានធនលើឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

ចំណាត់ថ្នាក់	ចំនួនថ្ងៃហួសកាលកំណត់សង	ប្រភេទ សំវិធានធន	កំរិតសំវិធានធន
ធម្មតា	- តិចជាង 15ថ្ងៃ (កាលកំណត់ដំបូងតិចជាង ឬ ស្មើមួយឆ្នាំ) - តិចជាង 30ថ្ងៃ (កាលកំណត់ដំបូងលើសមួយឆ្នាំ)	សំវិធានធន ទូទៅ	1%
ឃ្លាំមើល	- 15ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងតិចជាង ឬ ស្មើមួយឆ្នាំ) - 30ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងលើសមួយឆ្នាំ)	សំវិធានធន ជាក់លាក់	3%
ក្រោមធម្មតា	- 31ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងតិចជាង ឬ ស្មើមួយឆ្នាំ) - 90ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងលើសមួយឆ្នាំ)	សំវិធានធន ជាក់លាក់	20%
ជាប់សង្ស័យ	- 61ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងតិចជាង ឬ ស្មើមួយឆ្នាំ) - 180ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងលើសមួយឆ្នាំ)	សំវិធានធន ជាក់លាក់	50%
បាត់បង់	- 91ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងតិចជាង ឬ ស្មើមួយឆ្នាំ) - 360ថ្ងៃ ឬលើសពីនេះ (កាលកំណត់ដំបូងលើសមួយឆ្នាំ)	សំវិធានធន ជាក់លាក់	100%

អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទាន និងបុរេប្រទានត្រូវបានចាត់ចំណាត់ថ្នាក់ដោយយោងទៅតាមសមត្ថភាព នៃការទូទាត់សងរបស់ដៃគូពាណិជ្ជកម្ម ។ នៅពេលមានព័ត៌មានដែលអាចទុកចិត្តបានថាបំណុលបាត់បង់ កើតមានឡើងច្រើនជាងតម្រូវការអប្បបរមានោះ សំវិធានធនបន្ថែមនឹងត្រូវបានគេធ្វើឡើង ។ អនុលោមទៅតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឥណទានហួសកាលកំណត់ត្រូវបានកំណត់ថា ប្រាក់ដើមសរុបនៅសល់នៅពេលដែលប្រាក់ដើម ឬការប្រាក់ហួសកាលកំណត់ ។

ការប្រមូលមកវិញចំពោះឥណទានដែលបានលុបចោលពីមុន និងការបញ្ចូលមកវិញនូវសំវិធានធនដែលមានពីមុនត្រូវបានបង្ហាញដាច់ដោយឡែកពីសំវិធានធនសុទ្ធ របស់ឥណទានអាក្រក់និងជាប់សង្ស័យក្នុងគណនីលទ្ធផល ។

ឥណទានដែលមិនអាចទារបាន ឬចំណែកនៃឥណទានដែលបានចាត់ថ្នាក់ជាឥណទានអាក្រក់ ត្រូវបានកាត់ចេញបន្ទាប់ពីពិចារណាទៅលើតម្លៃលក់បាននៃទ្រព្យបញ្ចាំ ប្រសិនបើមាន នៅពេលដែលថ្នាក់ដឹកនាំវិនិច្ឆ័យថាពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញ ។

2.12 ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាទៅតាមតម្លៃដើម។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងសម្រាប់ទ្រព្យសកម្មដែលជាប់សង្ស័យ ដោយផ្អែកលើការពិនិត្យឡើងវិញនៃចំនួនទឹកប្រាក់ដែលនៅសល់នៅកាលបរិច្ឆេទរបាយការណ៍។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.13 ទ្រព្យរឹបអូសបាន

ទ្រព្យរឹបអូសរួមមាន ចលនទ្រព្យ និងអចលនទ្រព្យ ដោយយកតាមតម្លៃទាបជាងរវាងសមតុល្យឥណទាននៅសល់ និងតម្លៃសមស្របប៉ាន់ស្មាននៃទ្រព្យសម្បត្តិនោះនៅថ្ងៃរឹបអូសបាន ។ ចំណេញ ឬ ខាតពីការលក់ចេញ នៃទ្រព្យរឹបអូសបានត្រូវបានទទួលស្គាល់នៅក្នុងគណនីលទ្ធផលនៅថ្ងៃលក់ចេញ ។

2.14 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមាន កម្មវិធីកុំព្យូទ័ ដែលត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានកត់ត្រាជាទ្រព្យសកម្មដោយផ្អែកលើមូលដ្ឋាននៃថ្លៃដើមទិញ ហើយអាចយកទៅប្រើប្រាស់បាន។ ទ្រព្យសកម្មអរូបី ត្រូវបានដករំលស់ដោយប្រើវិធីសាស្ត្ររំលស់ថយចុះជាលំដាប់ក្នុងអត្រា 20% ក្នុងមួយឆ្នាំ ។

2.15 ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមតម្លៃដើមដោយដកបន្ថយនូវរំលស់បង្គរ និងការខាតបង់ ដោយសារការថយចុះនៃតម្លៃ។ តម្លៃដើមរាប់បញ្ចូលថ្លៃទិញ និងចំណាយផ្សេងៗដែលទាក់ទងផ្ទាល់នឹងការទិញអចលនទ្រព្យក្នុងគោលបំណងប្រើប្រាស់។ តាមករណីជាក់ស្តែង ថ្លៃដើមបន្តបន្ទាប់ត្រូវបានបញ្ចូលទៅក្នុងតម្លៃយោង ឬទទួលស្គាល់ជាទ្រព្យសកម្មមួយផ្សេងទៀត តែនៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ចទៅអនាគតដែលពាក់ព័ន្ធជាមួយនឹងទ្រព្យនោះនឹងហូរចូលមកធនាគារ និង ថ្លៃដើមនៃធាតុនោះអាចត្រូវបានវាស់វែងដោយជឿទុកចិត្តបាន។ រាល់ការជួសជុល និងការថែទាំត្រូវបានកត់ត្រាក្នុងគណនីលទ្ធផលនៅក្នុងការិយបរិច្ឆេទដែលការជួសជុល និងថែទាំនោះបានកើតឡើង ។

រំលស់ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងគណនីលទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថយចុះ (លើកលែងតែ អគារ និងការជួសជុលកែលំអ ត្រូវបានធ្វើរំលស់ដោយផ្អែកលើមូលដ្ឋានរំលស់ថេរ) ដោយប្រើប្រាស់តម្លៃយោងនៃទ្រព្យសកម្មនីមួយៗនៅដើមការិយបរិច្ឆេទតាមអត្រាដូចខាងក្រោម។

ប្រភេទអចលនទ្រព្យ	អត្រារំលស់	វិធីសាស្ត្ររំលស់
អគារ	5%	រំលស់ថេរ
ការជួសជុលកែលំអ	10%	រំលស់ថេរ
យានយន្ត	12.50%	រំលស់ថយចុះ
សម្ភារកំព្យូទ័រ	25%	រំលស់ថយចុះ
គ្រឿងបំពាក់ និងគ្រឿងសង្ហារឹម	12.50%	រំលស់ថយចុះ

តម្លៃយោងរបស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយភ្លាមមកត្រឹមតម្លៃអាចស្រង់មកបានវិញរបស់វា ប្រសិនបើតម្លៃយោងមានចំនួនធំជាងតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន ។ តម្លៃអាចស្រង់មកវិញបាន គឺជាតម្លៃខ្ពស់ជាងគេរវាងតម្លៃសមស្របដកចេញសោហ៊ុយលក់ និង តម្លៃប្រើប្រាស់របស់វា ។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.15 ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

ធាតុនៃអចលនទ្រព្យនីមួយៗ ត្រូវបានឈប់ទទួលស្គាល់នៅពេលមានការលក់ ឬដកចេញរបស់វា ឬនៅពេលពុំមានអត្ថប្រយោជន៍សេដ្ឋកិច្ចទៅអនាគត ដែលត្រូវបានរំពឹងទុកពីការប្រើប្រាស់របស់វា ឬការលក់ ឬដកចេញរបស់វា។ ចំណេញ ឬខាត ពីការបោះចោល ឬការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃទ្រព្យ និងបរិក្ខារនោះហើយត្រូវបានទទួលស្គាល់នៅក្នុងគណនីលទ្ធផលនៅថ្ងៃបោះចោល ឬលក់ចេញ ។

ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ ឬលុបចោល ។

2.16 ការថយចុះតម្លៃនៃតម្លៃទ្រព្យសកម្ម

(ក). ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាការិយបរិច្ឆេទនៃការធ្វើរបាយការណ៍ដើម្បីកំណត់ថាតើ មានភស្តុតាងណាមួយដែលបង្ហាញថា ឱនភាពអាចកើតមានឡើង ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវចាត់ទុកថាមានឱនភាពក្នុងករណីដែលអាចបង្ហាញថា មានហេតុការណ៍មួយ ឬច្រើនជះឥទ្ធិពលអវិជ្ជមានទៅលើចលនាទឹកប្រាក់នាពេលអនាគតនៃទ្រព្យសកម្មនោះ ។ ករណីនេះមិនត្រូវបានប្រើប្រាស់សម្រាប់ឥណទាន និងបុរេប្រទានដែល ត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកនៅក្នុងកំណត់សំគាល់ 2.10 និង 2.11 ។

ទ្រព្យសកម្មហិរញ្ញវត្ថុសំខាន់ៗនីមួយៗ ត្រូវបានធ្វើតេស្តសំរាប់ការថយចុះតម្លៃរៀងៗខ្លួន ។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលនៅសេសសល់ត្រូវបានវាយតម្លៃរួមគ្នាជាក្រុមដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា។

ការខាតបង់លើឱនភាព ត្រូវបានដាក់ចូលជាបន្ទុកនៅក្នុងគណនីលទ្ធផល នៅក្នុងការិយបរិច្ឆេទដែលវាកើតឡើង។ បន្ទាប់ពីមានការទទួលស្គាល់ការខាតបង់លើឱនភាព ធនាគារអាចកត់ត្រាបញ្ច្រាស់នៃការខាតបង់វិញ ប្រសិនបើមានព្រឹត្តិការណ៍ប្រាកដថាការខាតបង់នេះអាចយកមកវិញ។

(ខ). ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុដើម្បីកំណត់ថាតើមានកត្តាដែលនាំឲ្យមានឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង ។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារដកចំណាយលក់ចេញ ។ ក្នុងការវាយតម្លៃលើតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួល

ធនាគារ អភិវឌ្ឍន៍ ជនបទ

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

បាននាពេលអនាគត ត្រូវបានបញ្ចុះទៅតម្លៃបច្ចុប្បន្នដោយប្រើប្រាស់អត្រាការប្រាក់មុនដកពន្ធ ដែលឆ្លុះបញ្ចាំងតម្លៃទីផ្សារផ្អែកលើតម្លៃនៃពេលវេលា និង ហានិភ័យជាក់លាក់នៃទ្រព្យសកម្មទាំងនោះ ។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.16 ការថយចុះតម្លៃនៃតម្លៃទ្រព្យសកម្ម (តពីទំព័រមុន)

(ខ). ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (តពីទំព័រមុន)

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាព តម្លៃទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាទៅក្រុមតូចៗនៃទ្រព្យសកម្មដែលបង្កើតលំហូរចូលសាច់ប្រាក់ពីការបន្តប្រើប្រាស់ ដែលមិនពឹងផ្អែកខ្លាំងលើលំហូរចូលសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬ ក្រុមទ្រព្យសកម្មដទៃទៀត ("ឯកតាបង្កើតសាច់ប្រាក់") ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកវិញបាន។ ការខាតបង់ពីឱនភាពនៃតម្លៃត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផល ។

2.17 ទ្រព្យអកម្ម

ប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមតម្លៃដែលបានដាក់តម្កល់។ ចំណាយបង្គរ និងបំណុលផ្សេងៗត្រូវបានបង្ហាញតាមតំលៃដើមពិត ដែលជាតំលៃសមស្រប ដែលរំពឹងថាត្រូវបង់នាពេលអនាគតសំរាប់ទំនិញ ឬសេវាកម្មដែលទទួលបាន ។

2.18 ការទទួលស្គាល់ប្រាក់ចំណូល

ចំណូលពីការប្រាក់លើឥណទាន និងបុរេប្រទាន និងប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ព្រមទាំងធនាគារនានាត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរជារៀងរាល់ថ្ងៃ ។ នៅពេលដែលគណនី ត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការ ការប្រាក់នឹងត្រូវព្យួរទុកលុះត្រាតែវាទទួលបានជាសាច់ប្រាក់សុទ្ធ ។ ឥណទានចំពោះអតិថិជនត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការ នៅពេលដែលឥណទាននោះត្រូវបានចាត់ថ្នាក់ជាឥណទានក្រោមធម្មតា ជាប់សង្ស័យ ឬ បាត់បង់។

ចំណូលពីសកម្មភាពផ្សេងៗរបស់ធនាគារ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានដូចខាងក្រោម។

- កម្រៃពីកិច្ចសន្យាផ្តល់ឥណទាន និងកម្រៃជើងសារលើសេវាកម្ម និងឥណទានដែលបានផ្តល់ទៅ ឲ្យអតិថិជនត្រូវបានទទួលស្គាល់ជាចំណូលតែម្តងនៅពេលប្រតិបត្តិការកើតឡើង សម្រាប់ឥណទានរយៈពេលខ្លី និងទទួលស្គាល់ប្រចាំឆ្នាំផ្អែកតាមសមតុល្យនៅដើមការិយបរិច្ឆេទនីមួយៗ សម្រាប់ឥណទានរយៈពេលវែង។
- ហ្វាស៊ីលីធីដែលបានពន្យារជូនអតិថិជនត្រូវបានទទួលស្គាល់ជាចំណូលទៅតាមកាលកំណត់ នៃហ្វាស៊ីលីធីដែលបានពន្យារនោះ ។
- កម្រៃសេវាកម្ម និងកម្រៃរត់ការត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ ។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.19 ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ ឬខាតក្នុងការិយបរិច្ឆេទរួមមាន ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទត្រូវបានទទួលស្គាល់នៅក្នុងគណនីលទ្ធផល លើកលែងតែក្នុងករណីដែលពន្ធនោះទាក់ទងទៅនឹងសមាសធាតុដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ក្នុងករណីនេះក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ផងដែរ ។

ពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទ គឺជាពន្ធដែលនឹងត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធក្នុងការិយបរិច្ឆេទដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅថ្ងៃតារាងតុល្យការជាមួយនឹងនិយ័តកម្មណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារត្រូវបានកំណត់ ទៅលើភាពលំអៀងជាបណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និង តម្លៃដែលប្រើក្នុងគោលបំណងនៃការគិតពន្ធ ។ តម្លៃនៃពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើងរវាងតម្លៃសុទ្ធនៃទ្រព្យសកម្ម និងបំណុលដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតុល្យការ។

ពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម ។ ពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានកាត់បន្ថយក្នុងករណីដែលមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន ។

2.20 សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការ នៅពេលដែលធនាគារជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ឬកិច្ចសន្យាដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន និងអាចមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្តសំវិធានធនត្រូវបានកំណត់ដោយការបញ្ចុះតម្លៃចលនាសាច់ប្រាក់ ដែលរំពឹងទុកនាពេលអនាគតតាមអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ន តាមតម្លៃពេលវេលានៃប្រាក់កាស និងដោយសមស្របទៅនឹង ហានិភ័យជាក់លាក់នៃបំណុល ។

2.21 ភតិសន្យាប្រតិបត្តិការ

ថ្លៃឈ្នួលដែលបានបង់ លើភតិប្រតិបត្តិការត្រូវបានទទួលស្គាល់ក្នុងគណនីលទ្ធផលតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ទាយជ្ជទានលើភតិសន្យា មិនត្រូវបានទទួលស្គាល់ជាបំណុលរហូតដល់កាតព្វកិច្ចត្រូវទូទាត់ដល់ពេលកំណត់ ។

2. គោលការណ៍ គណនេយ្យសង្ខេបសំខាន់ៗ (តពីទំព័រមុន)

2.22 សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិរបស់ធនាគារ ប្រសិនបើភាគីមួយមានលទ្ធភាពគ្រប់គ្រង ដោយផ្ទាល់ ឬដោយប្រយោលលើភាគីមួយទៀត ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាគីនេះក្នុងការធ្វើសេចក្ដីសម្រេចលើផ្នែក ហិរញ្ញវត្ថុ និងប្រតិបត្តិការ ។ ដូចគ្នានេះដែរប្រសិនបើធនាគារ និងភាគី នោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលយ៉ាងខ្លាំង ។

សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល និងរួមបញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់នៃសមាជិកគ្រួសារ ដែលជិតស្និទ្ធិក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិដែរ ។

អនុលោមតាមច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និយមន័យរបស់សម្ព័ន្ធញាតិរួមបញ្ចូលផងដែរនូវរូបវន្ត បុគ្គលដែលមានភាគហ៊ុនយ៉ាងតិចចំនួន 10% នៃដើមទុនរបស់ធនាគារ ឬនៃសិទ្ធិបោះឆ្នោត ទោះកាន់កាប់ ដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ឬរូបវន្តបុគ្គលណាដែលរួមចំណែកក្នុងផ្នែករដ្ឋបាល ការដឹកនាំ ការគ្រប់គ្រង ឬការរៀបចំ និងការអនុវត្តនូវការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ។

2.23 ការកាត់ខ្ទង់នៃចំនួនទឹកប្រាក់

ចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ បានត្រូវកាត់ខ្ទង់ជាចំនួនគត់ឯកតាដុល្លាអាមេរិកចំពោះចំនួនទឹកប្រាក់ ដុល្លាអាមេរិក និង ឯកតាពាន់រៀលចំពោះចំនួនទឹកប្រាក់រៀល។

3. ការវិនិច្ឆ័យ និង ការប៉ាន់ប្រមាណលើគណនេយ្យ

ការប៉ាន់ប្រមាណ និងការវិនិច្ឆ័យ ត្រូវបានធ្វើការវាយតំលៃជាបន្តបន្ទាប់ ផ្អែកលើបទពិសោធន៍កន្លងមក និងកត្តា ផ្សេងៗ ដូចជាការរំពឹងទុកនូវហេតុការណ៍នាពេលអនាគត ដែលគេជឿថាមានភាពសមហេតុផល ទៅតាម កាលៈទេសៈផ្សេងៗ ។ លទ្ធផលនៃការប៉ាន់ប្រមាណគណនេយ្យ អាចខុសពីលទ្ធផលជាក់ស្ដែងដែលពាក់ព័ន្ធ ។ ការប៉ាន់ប្រមាណ និងសន្មត់ទៅលើហានិភ័យជាសារវន្ដ ដែលបណ្ដាលអោយមានការកែតម្រូវធំដុំចំពោះតំលៃក្នុង បញ្ជីដែលនៅសល់នៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានធ្វើការពិភាក្សាដូចខាងក្រោមៈ

(ក) ការខាតបង់លើការអន់ថយ នៃឥណទាន ចំពោះអតិថិជន

ធនាគារត្រូវបានតំរូវអោយគោរពតាមការបែងចែកចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមប្រកាស ស្ដីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន នៅក្នុងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា តំរូវអោយធនាគារទាំងឡាយធ្វើចំណាត់ថ្នាក់ ឥណទាន បុរេប្រទាន និងទ្រព្យសកម្មប្រហាក់ប្រហែលរបស់ខ្លួន ជា 5 ថ្នាក់ ហើយកំរិតអប្បបរមានៃសំវិធានធន ជាក់លាក់តាមបទបញ្ញត្តិ ត្រូវបានធ្វើឡើងដោយអាស្រ័យលើការធ្វើចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតដល់

ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុធានា ។ ក្នុងគោលបំណងបែងចែកចំណាត់ថ្នាក់ឥណទាន តំរូវឱ្យធនាគារពិចារណាទៅលើហានិភ័យ និងកត្តាពាក់ព័ន្ធទាំងអស់ ដែលអាចប៉ះពាល់ដល់លទ្ធភាពសងរបស់ "អ្នកខ្ចី" ។

3. ការវិនិច្ឆ័យ និង ការប៉ាន់ប្រមាណលើគណនេយ្យ (តពីទំព័រមុន)

(ខ) អចលនទ្រព្យ

គណនេយ្យលើអចលនទ្រព្យពាក់ព័ន្ធនឹងការប៉ាន់ប្រមាណ ដើម្បីកំណត់អាយុកាលប្រើប្រាស់ដែលរំពឹងទុករបស់វា។ ការកំណត់អាយុកាលប្រើប្រាស់របស់អចលនទ្រព្យ គឺផ្អែកតាមការវិនិច្ឆ័យរបស់ថ្នាក់ដឹកនាំ។

4. សាច់ប្រាក់

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
សាច់ប្រាក់ក្នុងដៃ - ដុល្លារអាមេរិក	1,698,831	6,825,903	2,099,204
សាច់ប្រាក់ក្នុងដៃ - រៀល	68,757	276,266	82,242
	1,767,588	7,102,169	2,181,446

5. សមតុល្យនៅធនាគារនានា

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ធនាគារកាណាឌីយ៉ា ភីអិលស៊ី	788,201	3,166,992	4,029,541
ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី	40,561	162,974	643,351
ធនាគារអេស៊ីលីដា ភីអិលស៊ី	72,477	291,212	342,821
	901,239	3,621,178	5,015,713

ការវិភាគបន្ថែមមានដូចតទៅ ៖

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
(ក) តាមកាលកំណត់ ៖			
រយៈពេល 1 ខែ	901,239	3,621,178	5,015,713
(ខ) តាមរូបិយប័ណ្ណ ៖			
ប្រាក់រៀល	125,622	504,749	422,495
ប្រាក់ដុល្លារអាមេរិក	775,617	3,116,429	4,593,218
	901,239	3,621,178	5,015,713

(គ) តាមទំនាក់ទំនង៖

ភាគីមិនមែនសម្ព័ន្ធញាតិ	901,239	3,621,178	5,015,713

6. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
គណនីចរន្ត (ក)	12,005,183	48,236,825	6,375,374
វិញ្ញាបនបត្រប្រាក់បញ្ញើចរចារ (NCD) (ខ)	719,776	2,892,060	21,549,542
	12,724,959	51,128,885	27,924,916
ប្រាក់បញ្ញើតម្កល់តាមច្បាប់លើ៖			
ប្រាក់តម្កល់ធានាលើដើមទុន (គ)	1,635,175	6,570,133	1,486,604
ប្រាក់បញ្ញើតម្កល់របស់អតិថិជន (ឃ)	208,711	838,601	158,670
	1,843,886	7,408,734	1,645,274
	14,568,845	58,537,619	29,570,190

(ក) **គណនីចរន្ត:** គណនីនេះមិនទទួលបានការប្រាក់ទេ ។

(ខ) វិញ្ញាបនបត្រប្រាក់បញ្ញើចរចារ (NCD)

ធនាគារបានសន្យាដាក់វិញ្ញាបនបត្រប្រាក់បញ្ញើចរចារធ្វើជាទ្រព្យបញ្ចាំ នៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការទូទាត់សង។ វិញ្ញាបនបត្រប្រាក់បញ្ញើរចរចារមានរយៈពេលបីខែ និងទទួលបានអត្រាការប្រាក់ 0.24% - 1.01% សំរាប់បញ្ញើជាប្រាក់ដុល្លា និង 1.43% សំរាប់បញ្ញើជាប្រាក់រៀលក្នុងមួយឆ្នាំ (2017: 0.24% - 1.01% សំរាប់បញ្ញើជាប្រាក់ដុល្លា និង 1.43% សំរាប់បញ្ញើជាប្រាក់រៀលក្នុងមួយឆ្នាំ) ។

(គ) ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសលេខ ធ7-06-208 ចុះថ្ងៃទី 13 ខែ កញ្ញា ឆ្នាំ 2006 ស្តីពីវិសោធនកម្មលើមាត្រា 9 និង 13 នៃប្រកាស លេខ ធ7-00-05 ស្តីពីអាជ្ញាប័ណ្ណធនាគារឯកទេស តំរូវអោយធនាគារឯកទេសតម្កល់ប្រាក់ធានាលើដើមទុនអប្បបរមាស្មើនឹង 5% នៃដើមទុនចុះបញ្ជីរបស់ធនាគារជាមួយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះមិនអាចដកមកបំរើប្រតិបិត្តការប្រចាំថ្ងៃរបស់ធនាគារបានទេ ប៉ុន្តែនឹងសងត្រឡប់ទៅវិញនៅពេលធនាគារបញ្ចប់ប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

(ឃ) ប្រាក់តម្កល់បម្រុងកាតព្វកិច្ច

ប្រាក់បញ្ញើនេះ គឺជាប្រាក់តម្កល់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន ដែលប្រែប្រួលដោយផ្អែកទៅលើកម្រិតប្រែប្រួលនៃប្រាក់បញ្ញើរបស់អតិថិជននៅធនាគារ ។ ប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវរក្សាទុក ស្របតាម

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

ប្រកាសលេខ ប7-00-05ប្រក ចុះថ្ងៃទី 11 ខែ មករា ឆ្នាំ 2000 ស្តីពីប្រាក់តម្កល់បម្រុងកាតព្វកិច្ចតាមអត្រា 5% លើប្រាក់បញ្ញើរបស់អតិថិជន ។

6. **សមតុល្យនៅធនាគារជាតិនៃកម្ពុជា** (តពីទំព័រមុន)

(ង) ប្រាក់តម្កល់ធានាលើដើមទុន និងប្រាក់តម្កល់បម្រុងកាតព្វកិច្ចទទួលបានការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម៖

	2018	2017
ប្រាក់តម្កល់ធានាលើដើមទុន	0.32% - 0.36%	0.22% - 3.00%
5% ប្រាក់តម្កល់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន ជាប្រាក់រៀល	គ្មាន	គ្មាន
5% ប្រាក់តម្កល់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន ជារូបិយប័ណ្ណបរទេស	គ្មាន	គ្មាន

7. **ឥណទាន និងបុរេប្រទាន - សុទ្ធ**

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ឥណទានរយៈពេលវែង	102,303,592	411,055,831	85,917,320
ឥណទានរយៈពេលខ្លី	55,021,078	221,074,693	35,483,938
ឥណទានបុគ្គលិក	1,790,538	7,194,382	669,728
សរុបឥណទាន - ដុល	159,115,208	639,324,906	122,070,986
សំវិធានធនឥណទាន និងបុរេប្រទានអាក្រក់និងជាប់សង្ស័យ	(6,304,442)	(25,331,248)	(4,769,307)
	152,810,766	613,993,658	117,301,679

បម្រែបម្រួលនៃសំវិធានធនសម្រាប់ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ មានដូចខាងក្រោម៖

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
នាថ្ងៃទី 01 មករា	4,769,307	19,163,076	3,122,480
ការបន្ថែមក្នុងការិយបរិច្ឆេទ	1,535,135	6,168,172	1,646,827
នៅចុងឆ្នាំ	6,304,442	25,331,248	4,769,307

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

7. ឥណទាន និងបុរេប្រទាន - សុទ្ធ (តពីទំព័រមុន)

ការវិភាគបន្ថែមមានដូចតទៅ ៖

(ក) វិភាគតាមកាលកំណត់សង ៖	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
1 ទៅ 3 ខែ	5,280,000	21,215,040	-
3 ទៅ 6 ខែ	800,000	3,214,400	19,740,000
6 ទៅ 12 ខែ	48,158,266	193,499,913	12,510,771
1 ទៅ 3 ឆ្នាំ	12,744,629	51,207,919	8,663,350
3 ទៅ 5 ឆ្នាំ	41,886,381	168,299,479	14,252,734
លើសពី 5 ឆ្នាំ	50,245,932	201,888,155	66,904,131
	159,115,208	639,324,906	122,070,986
(ខ) វិភាគតាមរូបិយប័ណ្ណ៖			
ប្រាក់ដុល្លារអាមេរិក	155,832,898	626,136,584	118,728,831
ប្រាក់រៀល	3,282,310	13,188,322	3,342,155
	159,115,208	639,324,906	122,070,986
(គ) វិភាគតាមការស្នាក់នៅ ៖			
និវាសនជន	159,115,208	639,324,906	122,070,986
(ឃ) ការវិភាគតាមចំណាត់ថ្នាក់ឥណទាន ៖			
ឥណទានស្តង់ដារ ៖			
មានវត្ថុធានា	92,106,372	370,083,403	80,318,575
ពុំមានវត្ថុធានា	52,026,350	209,041,874	35,411,000
ឥណទានឃ្លាំមើល ៖			
មានវត្ថុធានា	8,792,341	35,327,626	2,490,000
ពុំមានវត្ថុធានា	500,000	2,009,000	-
ឥណទានក្រោមធម្មតា ៖			
មានវត្ថុធានា	976,000	3,921,568	143,000
ពុំមានវត្ថុធានា	-	-	-
ឥណទានជាប់សង្ស័យ ៖			
មានវត្ថុធានា	600,000	2,410,800	349,400
ពុំមានវត្ថុធានា	50,000	200,900	50,000
ឥណទានបាត់បង់ ៖			
មានវត្ថុធានា	2,179,145	8,755,805	3,286,073
ពុំមានវត្ថុធានា	1,885,000	7,573,930	22,938
	159,115,208	639,324,906	122,070,986

7. ឥណទាន និងបុរេប្រទាន - សុទ្ធ (តពីទំព័រមុន)

ឥណទានដែលមានវត្ថុធានាគឺតំណាងអោយឥណទាន ទៅអោយអតិថិជនដែលដាក់បញ្ចាំប្លង់ដី អគារ និង/ឬ ទ្រព្យអចលត៍ផ្សេងៗ ។

	2018		2017
(ង) វិភាគតាមសម្ព័ន្ធភាគី ៖	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ពុំមែនភាគីសម្ព័ន្ធញាត្តិ	157,324,670	632,130,524	121,401,258
ឥណទានបុគ្គលិក	1,790,538	7,194,382	669,728
	159,115,208	639,324,906	122,070,986
(ច) វិភាគតាមប្រភេទអតិថិជន ៖			
ក្រុមហ៊ុន	157,324,670	632,130,524	121,401,259
រូបវន្តបុគ្គល និង សហគ្រាសឯកត្តបុគ្គល	1,790,538	7,194,382	669,727
	159,115,208	639,324,906	122,070,986
(ឆ) វិភាគតាមគំរោង ៖			
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	27,180,000	109,209,240	27,365,000
មូលនិធិធនាគារអភិវឌ្ឍន៍ជនបទ	57,316,117	230,296,158	46,362,896
ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)	445,797	1,791,212	557,870
រាជរដ្ឋាភិបាលកម្ពុជា-មូលនិធិពិសេស	74,173,294	298,028,296	47,785,220
	159,115,208	639,324,906	122,070,986
(ជ) វិភាគតាមវិស័យសេដ្ឋកិច្ច ៖			
វិស័យឯកជន	154,607,277	621,212,039	116,709,247
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី	780,000	3,134,040	3,249,370
ស្ថាប័នហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ	564,086	2,266,498	124,771
សហគមន៍	927,510	3,726,735	760,000
ចំការកៅស៊ូជាលក្ខណៈគ្រួសារ	445,797	1,791,212	557,870
ឥណទានបុគ្គលិក	1,790,538	7,194,382	669,728
	159,115,208	639,324,906	122,070,986

7. ឥណទាន និងបុរេប្រទាន - សុទ្ធ (តពីទំព័រមុន)

(ឈ) វិភាគតាមហានិភ័យ ៖	2018 ដុល្លារអាមេរិក	2018 ពាន់រៀល	2017 ដុល្លារអាមេរិក
ហានិភ័យធំ (*)	71,605,294	287,710,071	60,051,220
ពុំមែនហានិភ័យធំ	87,509,914	351,614,835	62,019,766
	159,115,208	639,324,906	122,070,986

ហានិភ័យធំៗ ត្រូវបានផ្តល់និយមន័យនៅក្នុងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាថាជាសមតុល្យសរុបនៃឥណទាន និងបុរេប្រទាន ដែលផ្តល់ដល់អតិថិជនម្នាក់លើសពី 10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ហានិភ័យនេះសំដៅលើចំនួនប្រាក់ខ្ពស់បំផុតរវាងសមតុល្យនៃឥណទាន និងទាយជ្ជទានដែលនៅសល់ឬឥណទាន និងទាយជ្ជទានដែលបានអនុម័ត ។

(ញ) វិភាគតាមការប្រាក់ប្រចាំឆ្នាំ ៖	2018	2017
ឥណទានរយៈពេលខ្លី	5.00%-12.00%	5.00%-12.00%
ឥណទានរយៈពេលវែង	5.00%-12.00%	5.00%-12.00%
ឥណទានបុគ្គលិក	6.00%	6.00%

8. អចលនទ្រព្យបានរឹបអូស

ទ្រព្យរឹបអូស ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិដែលរឹបអូសពីអតិថិជន ដែលពុំមានលទ្ធភាពសងបំណុល ។ សេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាតាមប្រកាសលេខ ធ7-01-186 ទាមទារឲ្យទ្រព្យសម្បត្តិដែលបានរឹបអូសត្រូវលក់ចេញនៅក្នុងរយៈពេល 12 ខែ បន្ទាប់ពីរឹបអូសបាន ។

	2018				2017
	ដីធ្លី និងអគារ	បរិក្ខារ		សរុប	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
សមតុល្យដើមគ្រា	1,150,719	341,720	1,492,439	5,996,620	1,466,120
បន្ថែមក្នុងឆ្នាំ	1,736,369	-	1,736,369	6,976,731	26,319
ដកៈ លក់ចេញក្នុងឆ្នាំ	(18,819)	-	(18,819)	(75,615)	-
	2,868,269	341,720	3,209,989	12,897,736	1,492,439
ដកៈ សំវិធានធនសម្រាប់ឱនភាព	-	(334,055)	(334,055)	(1,342,233)	(334,055)
សមតុល្យចុងគ្រា	2,868,269	7,665	2,875,934	11,555,503	1,158,384

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ធនាគារមិនទាន់បានលក់ចេញទ្រព្យដែលរឹបអូសបានតាំងពីខែ តុលា ឆ្នាំ 2012 នៅឡើយទេ ហើយសំណើសម្រាប់ពន្យាពេលបន្ថែមដើម្បីកាន់កាប់ទ្រព្យរឹបអូសទាំងនេះទៅធនាគារជាតិនៃកម្ពុជានៅមិនទាន់ត្រូវបានធ្វើនៅឡើយ ។

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

8. អចលនទ្រព្យបានរឹបអូស (តពីទំព័រមុន)

បំរែបំរួលនៃសំវិធានធនសម្រាប់ទ្រព្យដែលរឹបអូសបាន ត្រូវបានបង្ហាញដូចខាងក្រោម៖

	2018		2017
	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក
សមតុល្យដើមគ្រា	334,055	1,342,233	334,055
ការបន្ថែមក្នុងការិយបរិច្ឆេទ	-	-	-
សមតុល្យចុងគ្រា	334,055	1,342,233	334,055

9. ទ្រព្យសកម្មផ្សេងទៀត

	2018		2017
	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក
ការប្រាក់បង្គរត្រូវទទួលបាន	3,517,576	14,133,620	2,402,265
ការប្រាក់ព្យួរទុក (*)	(1,435,107)	(5,766,260)	(1,199,214)
បុរេប្រទានទៅឱ្យអ្នកផ្គត់ផ្គង់	253,770	1,019,648	-
បុរេប្រទានលើធានារ៉ាប់រង	1,098	4,412	1,297
ការប្រាក់ត្រូវទទួល	11,836	47,557	11,830
បុរេប្រទានលើប្រេងឥន្ធនៈ	50,420	202,588	32,015
ផ្សេងៗ	73,346	294,704	84,579
	2,472,939	9,936,269	1,332,772

(*) ការប្រាក់សរុបព្យួរទុកត្រូវបានរាយការណ៍ថាមិនអាចផ្ទៀងផ្ទាត់បាន។ ប្រព័ន្ធឥណទានរបស់ធនាគារមិនអាចបង្កើតនូវព័ត៌មានពេញលេញដែលចាំបាច់ដើម្បីចាត់ថ្នាក់ការប្រាក់ត្រូវទទួលសម្រាប់ឥណទានមិនដំណើរការ។

10. ទ្រព្យសកម្មអរូបី

	2018		2017
ថ្លៃដើម	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក
នាថ្ងៃទី 1 មករា	169,557	681,280	164,880
ការទិញបន្ថែម	3,347	13,448	4,677
នាថ្ងៃទី 31 ធ្នូ	172,904	694,728	169,557
រំលស់បង្គរ			
នាថ្ងៃទី 1 មករា	150,772	605,802	134,710
ទាយជ្ជទានក្នុងការិយបរិច្ឆេទ	10,168	40,855	16,062
នាថ្ងៃទី 31 ធ្នូ	160,940	646,657	150,772
តម្លៃពិត	**11,964**	**48,071**	**18,785**

ធនាគារ អភិវឌ្ឍន៍ ជនបទ

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

11. ទ្រព្យ និងបរិក្ខារ

	ដីធ្លី	អគារ	កែលំអអគារ	យានយន្ត	សម្ភារះកុំព្យូទ័រ	សង្ហារឹម	សរុប
ថ្លៃដើម	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក	ដុល្លាអាមេរិក
នាថ្ងៃទី 1 មករា 2018	241,500	329,344	61,436	894,418	243,344	233,225	2,003,267
ទិញបន្ថែម	1,765,171	-	105,354	147,510	59,953	36,487	2,114,475
នាថ្ងៃទី 31 ធ្នូ 2018	2,006,671	329,344	166,790	1,041,928	303,297	269,712	4,117,742
រំលស់បង្គរ							
នាថ្ងៃទី 1 មករា 2018	-	144,555	40,468	532,260	204,024	125,568	1,046,875
ទាយជ្ជទានក្នុងការិយបរិច្ឆេទ	-	16,513	24,452	91,449	31,312	35,111	198,837
នាថ្ងៃទី 31 ធ្នូ 2018	-	161,068	64,920	623,709	235,336	160,679	1,245,712
តម្លៃពិត							
នាថ្ងៃទី 31 ធ្នូ 2018	**2,006,671**	**168,276**	**101,870**	**418,219**	**67,961**	**109,033**	**2,872,030**
នាថ្ងៃទី 31 ធ្នូ 2017	**241,500**	**184,789**	**20,968**	**362,158**	**39,320**	**107,657**	**956,392**

ធនាគារ អភិវឌ្ឍន៍ ជនបទ

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018

11. ទ្រព្យ និងបរិក្ខារ(តពីទំព័រមុន)

សមមូលជាប្រាក់រៀល ៖ ថ្លៃដើម	ដីធ្លី ពាន់រៀល	អគារ ពាន់រៀល	កែលំអអគារ ពាន់រៀល	យានយន្ត ពាន់រៀល	សម្ភារកុំព្យូទ័រ ពាន់រៀល	សង្ហារឹម ពាន់រៀល	សរុប ពាន់រៀល
នាថ្ងៃទី 1 មករា 2018	970,347	1,323,304	246,850	3,593,772	977,756	937,098	8,049,127
ទិញបន្ថែម	7,092,457	-	423,312	592,695	240,891	146,605	8,495,960
នាថ្ងៃទី 31 ធ្នូ 2018	8,062,804	1,323,304	670,162	4,186,467	1,218,647	1,083,703	16,545,087
រំលស់បង្គរ							
នាថ្ងៃទី 1 មករា 2018	-	580,822	162,600	2,138,621	819,768	504,532	4,206,343
ទាយជ្ជទានក្នុងការិយបរិច្ឆេទ	-	66,349	98,248	367,442	125,812	141,076	798,927
នាថ្ងៃទី 31 ធ្នូ 2018	-	647,171	260,848	2,506,063	945,580	645,608	5,005,270
តម្លៃពិត							
នាថ្ងៃទី 31 ធ្នូ 2018	**8,062,804**	**676,133**	**409,314**	**1,680,404**	**273,067**	**438,095**	**11,539,817**
នាថ្ងៃទី 31 ធ្នូ 2017	**974,936**	**745,994**	**84,648**	**1,462,032**	**158,734**	**434,611**	**3,860,955**

12. ប្រាក់បញ្ញើរបស់អតិថិជន

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ប្រាក់បញ្ញើតាមតម្រូវការ	1,880,633	7,556,383	735,828
ប្រាក់បញ្ញើសន្សំ	580,462	2,332,296	944,611
ប្រាក់បញ្ញើមានកាលកំណត់	985,480	3,959,659	630,560
	3,446,575	13,848,338	2,310,999

ការវិភាគបន្ថែមអំពីប្រាក់បញ្ញើរបស់អតិថិជនមានដូចខាងក្រោម ៖

	2018		2017
(ក) វិភាគតាមកាលកំណត់សង ៖	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ត្រឹមមួយខែ ៖			
ប្រាក់បញ្ញើតាមតម្រូវការ	1,880,633	7,556,383	735,828
ប្រាក់បញ្ញើសន្សំ	580,462	2,332,297	944,611
ប្រាក់បញ្ញើមានកាលកំណត់៖			
1 ទៅ 3 ខែ	142,443	572,336	313,216
4 ទៅ 6 ខែ	5,800	23,304	5,590
6 ខែ ឡើងទៅ	837,237	3,364,018	311,754
	3,446,575	13,848,338	2,310,999
(ខ) វិភាគតាមប្រភេទអតិថិជន ៖			
អង្គភាពអាជីវកម្មក្នុងស្រុក	1,889,005	7,590,022	1,549,691
ឯកត្តជន	1,557,570	6,258,316	761,308
	3,446,575	13,848,338	2,310,999
(គ) វិភាគតាមការស្នាក់នៅ ៖			
និវាសនជន	3,444,879	13,841,523	2,280,624
អនិវាសនជន	1,696	6,815	30,375
	3,446,575	13,848,338	2,310,999
(ឃ) វិភាគតាមប្រភេទរូបិយប័ណ្ណ ៖			
ដុល្លារអាមេរិក	3,436,084	13,806,185	2,302,573
ប្រាក់រៀល	10,491	42,153	8,426
	3,446,575	13,848,338	2,310,999

12. ប្រាក់បញ្ញើរបស់អតិថិជន (តពីទំព័រមុន)

	2018	2017
(ង) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ) ៖		
គណនីសន្សំ	1.00%	1.00% - 1.50%
គណនីមានកាលកំណត់	3.00% - 5.00%	3.00% - 6.00%

13. ប្រាក់បញ្ញើរបស់ធនាគារនានា

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ប្រាក់បញ្ញើតាមតម្រូវការ	24,074	96,729	2,706
ប្រាក់បញ្ញើសន្សំ	695	2,793	47,756
	24,769	99,522	50,462

ការវិភាគបន្ថែមអំពីប្រាក់បញ្ញើរបស់ធនាគារនានា មានដូចខាងក្រោម ៖

	2018		2017
(ក) វិភាគតាមកាលកំណត់សង ៖	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
រយៈពេល 1 ខែ	24,769	99,522	50,462
(ខ) តាមរូបិយប័ណ្ណ៖			
ប្រាក់ដុល្លារអាមេរិក	24,769	99,522	49,952
ប្រាក់រៀល	-	-	510
	24,769	99,522	50,462
(គ) តាមនិវាសនដ្ឋាន៖			
និវាសនជន	24,769	99,522	50,462

	2018	2017
(ឃ) តាមអត្រាការប្រាក់ ៖ (ក្នុងមួយឆ្នាំ)		
ប្រាក់បញ្ញើតាមតម្រូវការ	គ្មាន	គ្មាន
ប្រាក់បញ្ញើសន្សំ	1.0%	1.0% - 1.50%

14. ប្រាក់កម្ចី

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
រាជរដ្ឋាភិបាលកម្ពុជា - មូលនិធិពិសេស	83,825,535	336,811,000	73,478,078
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ASDF)	39,385,000	158,248,930	37,455,000
ធនាគារអភិវឌ្ឍន៍អាស៊ី	385,101	1,547,336	576,769
ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)	248,461	998,316	248,461
IFAD	2,000,000	8,036,000	-
	125,844,097	505,641,582	111,758,308

ការវិភាគបន្ថែមអំពីប្រាក់កម្ចីមានដូចខាងក្រោម ៖

	2018		2017
(ក) វិភាគតាមកាលកំណត់សង ៖	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
រយៈពេល 1 ឆ្នាំ	11,520,000	46,287,360	12,060,000
1 ទៅ 3 ឆ្នាំ	14,000,000	56,252,000	-
3 ទៅ 5 ឆ្នាំ	25,865,000	103,925,570	25,395,000
5 ឆ្នាំ ឡើងទៅ	74,459,097	299,176,652	74,303,308
	125,844,097	505,641,582	111,758,308

	2018	2017
(ខ) តាមអត្រាការប្រាក់៖	% ប្រចាំឆ្នាំ	% ប្រចាំឆ្នាំ
រាជរដ្ឋាភិបាលកម្ពុជា - មូលនិធិពិសេស	គ្មាន	គ្មាន
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ASDF)	2.00%	2.00%
IFAD	1.5 %	-
ធនាគារអភិវឌ្ឍន៍អាស៊ី	1.29% - 3.67%	0.55% - 2.55%
ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)	គ្មាន	គ្មាន

15. ទ្រព្យអកម្មផ្សេងៗ

	2018		2017
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក
ការប្រាក់ត្រូវទូទាត់	1,478,944	5,942,397	960,131
មូលនិធិសន្តិសុខការងារ	-	-	359,378
បំណុលពន្ធផ្សេងៗ	49,207	197,714	8,844
ទ្រព្យអកម្មផ្សេងៗ	2,189,931	8,799,143	190,420
	3,718,082	14,939,254	1,518,773

16. ដើមទុន ដើមទុនបន្ថែម និង មូលធនបំរុង

(ក) ដើមទុន

	2018		2017
	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	22,035,837	88,539,993	20,475,890
ផ្ទេរទៅដើមទុន (កំណត់សំគាល់ 16 ខ)	2,926,920	11,760,365	1,559,947
	24,962,757	100,300,358	22,035,837

ដើមទុនចុះបញ្ជីរបស់ធនាគារបង្ហាញក្នុងលក្ខន្តិកៈកែសំរួលចុងក្រោយមានចំនួន 46,365,538 ដុល្លាអាមេរិក (187,177,680,000 រៀល) ចែកចេញជា 10,000 ភាគហ៊ុន ដែលមួយហ៊ុនមានតំលៃ 4,636.55 ដុល្លាអាមេរិក ។

(ខ) ដើមទុនបន្ថែម

	2018		2017
	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក
សមតុល្យនៅដើមគ្រា	10,700,928	42,996,329	9,319,136
ផ្ទេរទៅដើមទុន	(2,926,920)	(11,760,365)	(1,559,947)
បូក : សាច់ប្រាក់សងត្រឡប់នៃការផ្ទេរចេញឥណទានមិនដំណើរការទៅក្រៅតារាងតុល្យការ	181,040	727,419	2,941,739
	7,955,048	31,963,383	10,700,928

(i) នៅថ្ងៃទី 13 ខែ មករា ឆ្នាំ 2015 ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាភាគទុនិករបស់ធនាគារ បានដាក់បន្ថែមដើមទុនចំនួន 26,028,756 ដុល្លាអាមេរិក ។

(ii) យោងទៅតាមលិខិតលេខ 536 សហវ ចុះនៅថ្ងៃទី 3 ខែកុម្ភៈ ឆ្នាំ2016 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានដាក់ជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងចំណាររបស់សម្តេចចុះថ្ងៃទី 4 ខែ កុម្ភៈ ឆ្នាំ 2016 បានសម្រេចតាមសំណើរបស់ធនាគារអភិវឌ្ឍន៍ជនបទ លើវិធានមួយចំនួនដែលទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ 2015 ដែលមានដូចខាងក្រោម ៖

- ផ្ទេរចេញឥណទាននិងបុរេប្រទានមិនដំណើរការចំនួន 18,269,567 ដុល្លាអាមេរិកពីតារាងតុល្យការ ទៅគណនីក្រៅតារាងតុល្យការរបស់ធនាគារ ដើម្បីប្រមូលដោះស្រាយ និងប្រមូលមកវិញ ។
- ទទួលស្គាល់ឥណទាន និងបុរេប្រទានមិនដំណើរការចំនួន 18,269,567 ដុល្លារអាមេរិក ជាការកាត់បន្ថយដើមទុន ។
- ឥណទាន និងបុរេប្រទានមិនដំណើរការខាងលើដែលមានលទ្ធភាពស្តារបានឡើងវិញ នឹងត្រូវបាន ទទួលស្គាល់ដោយផ្ទាល់ក្នុងគណនីដើមទុនរបស់ធនាគារ ។

វិធានខាងលើនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 31 ខែ មីនា ឆ្នាំ 2016 ។

16. ដើមទុន, ដើមទុនបន្ថែម និង មូលធនបំរុង (តពីទំព័រមុន)

(ខ) ដើមទុនបន្ថែម (តពីទំព័រមុន)

(iii) នៅថ្ងៃទី 10 ខែកុម្ភៈ ឆ្នាំ 2017 ធនាគារបានស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីផ្ទេរទឹកប្រាក់ចំនួន 1,559,947 ដុល្លាអាមេរិក ដែលជាចំនួនទឹកប្រាក់ប្រមូលបានពីឥណទាន និងបុរេប្រទានមិនដំណើរការខាងលើទៅគណនីមូលធនបានបង់ជម្រះ ។ សំណើនេះត្រូវបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី 21 ខែ សីហា ឆ្នាំ 2017 ។

(iv) នៅថ្ងៃទី 28 ខែមិនា ឆ្នាំ 2017 ធនាគារបានស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីផ្ទេរទឹកប្រាក់ចំនួន 2,926,920 ដុល្លាអាមេរិក ដែលជាចំនួនទឹកប្រាក់ប្រមូលបានពីឥណទាន និងបុរេប្រទានមិនដំណើរការខាងលើទៅគណនីមូលធនបានបង់ជម្រះ ។ សំណើនេះត្រូវបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី 17 ខែកក្កដា ឆ្នាំ 2018 ។

(គ) មូលធនបំរុង

ចំនួនទឹកប្រាក់នេះគឺជាការប្រាក់ដែលប្រមូលបានមកវិញ របស់ឥណទាននិងបុរេប្រទានមិនដំណើរការដែលបានផ្ទេរទៅខាងក្រៅតារាងតុល្យការកាលពីឆ្នាំ 2015 ។ តាមការអះអាងរបស់ថ្នាក់ដឹកនាំធនាគារ ចំនួនទឹកប្រាក់នេះនឹងផ្ទេរទៅជាមូលធនបង់ជម្រះនៅពេលអនាគត។

17. អនុបំណុល

	2018		2017
	ដុល្លាអាមេរិក	ពាន់រៀល	ដុល្លាអាមេរិក
